# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល
## (អេឃ្វាប់)

EQUIP1

Educational Quality Improvement Program
Classrooms • Schools • Communities

# បំប៉នសិស្សរៀនយឺត



***ខែមករា ឆ្នាំ ២០០៧***

# ផែនការបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្រៀនបំប៉នសិស្សរៀនយឺត

| ជំហាន | ពេលវេលា | សកម្មភាព និង ខ្លឹមសារការបំប៉នបន្ថែម | ក្រុម | រយៈពេល | ឯកសារ |
|---|---|---|---|---|---|
| | | **ថ្ងៃទី ១** | | | |
| | | បែបបទទី១: ការរំលឹកទ្រឹស្តី និងគោលការណ៍ នៃការបំប៉នបន្ថែម | | | |
| 1 | 7: 30 – 7: 45 | ការណែនាំអោយស្គាល់គ្នា និងសំណេះសំណាលជាមួយសិក្ខាកាម | ធំ | ១៥នាទី | |
| 2 | 7:45 -7: 50 | អ្នកសម្របសម្រួលបង្ហាញគោលបំណង៣ :<br>-សិក្ខាកាមរៀបរាប់អំពីការបង្រៀនថ្នាក់បំប៉នបន្ថែមដោយ សង្កត់ធ្ងន់ទៅលើសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ។<br>-សិក្ខាកាមពន្យល់គោលការណ៍ខ្លះៗដែលទាក់ទងនិងសកម្មភាពបំប៉នបន្ថែម<br>-សិក្ខាកាមកំណត់គោលការណ៍មួយចំនួនដែលទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនជាក់ស្តែង ។ | ធំ | ៥នាទី | ក្រដាសផ្ទាំងធំ |
| 3 | 7:50 -8: 05 | សួរសិក្ខាកាម : - *អ្វីទៅដែលហៅថាការបំប៉នបន្ថែម?*<br>- *តើការបង្រៀនបំប៉នបន្ថែម មានលក្ខណៈដូចម្តេច ?*<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន។ | ធំ | ១៥នាទី | ក្រដាសផ្ទាំងធំ |
| 4 | 8:05 -8: 15 | - អ្នកសម្របសម្រួលបញ្ជាក់បន្ថែម<br>- ការបង្រៀនបំប៉នបន្ថែមមិនមែនជាការរៀនតាមកម្មវិធីសិក្សាសារឡើងវិញនោះទេ ។<br>- ជាការបង្រៀនទៅតាមសេចក្តីត្រូវការរបស់សិស្ស ។ | ធំ | ១០នាទី | |
| 5 | 8: 15-8: 20 | -បិទបង្ហាញដ្យាក្រាម និងពន្យល់ ទំព័រ ២ | ធំ | ៥នាទី | ក្រដាសផ្ទាំងធំ |
| 6 | 8:20 -8: 50 | ចែកករណីសិក្សាអោយសិក្ខាកាមអាននិងឆ្លើយសំណួរទាំង ៥ក្នុងទំព័រ ៣ | តូច | ៣០នាទី | ឯកសារចែក ទំព័រ ៣ |
| 7 | 8: 50- 9: 10 | **ចែកឯកសារគោលកាណ៍មូលដ្ឋាននៃការបំប៉នបន្ថែមទំព័រ ៤ អោយសិក្ខាកាមអានជាបុគ្គល និងពន្យល់បន្ថែម ទំព័រ ៤- ៥ រួមទាំងធ្វើលំហាត់ករណីសិក្សា។ អ្នកសម្របសម្រួលត្រូវទុកពេលអោយសិក្ខាកាមអាន និងរកចម្លើយរួមគ្នា។** | ធំ | ២០នាទី | ឯកសារចែក ទំព័រ ៤-៥ |
| | 9: 10 -9: 30 | **សម្រាក** | | ២០នាទី | |
| | | បែបបទទី២: កត្តាដែលនាំអោយសិស្ស ជួបបញ្ហាក្នុងការរៀន | | | |
| 8 | 9: 30-9: 35 | -បិទ និងបង្ហាញគោលបំណង ទំព័រ ៦ | ធំ | ៥នាទី | ក្រដាសផ្ទាំងធំ |
| 9 | 9:35- 9:50 | សួរសិក្ខាកាមថា តើមានកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើការរៀនរបស់សិស្ស?<br>-អ្នកសម្របសម្រួលពន្យល់កត្តាបង្រៀន ៣ យ៉ាងដែលមានឥទ្ធិពលលើការបង្រៀនសិស្ស មាននៅក្នុងទំព័រ ៦<br>កត្តាទី១ និងទី២ ជះឥទ្ធិពលផ្ទាល់លើការរៀនសូត្ររបស់សិស្ស | ធំ | ១៥នាទី | ក្រដាសផ្ទាំងធំ កត្តាទី១ ២ ៣ |

| | | | | | |
|---|---|---|---|---|---|
| | | កត្តាទី៣ទាក់ទងទៅនឹងស្ថានភាព*នៅផ្ទះ ផ្លូវចិត្ត និងអាកប្បកិរិយា* | | | |
| 10 | 9:50 -10:20 | **ល្បិចហាត់** : ចំណាត់ថ្នាក់វិញ្ញាណទាំង ៥<br>-<br>**ចែកប័ណ្ណល្បះនិងក្រដាសរ៉ាមធំអោយសិក្ខាកាមតាមក្រុមធ្វើចំណាត់ថ្នាក់អោយសិក្ខាកាមយកបណ្ណ័ល្បះទៅបិទតាមផ្នែកធំៗទាំង៣។**<br>- សម្របសម្រួលចម្លើយ | ធំ | ៣០នាទី | ប័ណ្ណល្បះ ទំព័រ៧-៨ |
| 11 | 10:20- 10:35 | -បិទបង្ហាញ ដ្យាក្រាមជុំវិលបរាជ័យ<br>- អ្នកសម្របសម្រួលពន្យល់បន្ថែម | ធំ | ១៥នាទី | ក្រដាសផ្ទាំងធំ |
| 12 | 10:35-11:15 | -អោយសិក្ខាកាមរកដំណោះស្រាយលើបញ្ហាទាំង ៣ ដែលមាននៅក្នុង ទំព័រ៧-៨<br>- អ្នកសម្របសម្រួលចែកបញ្ជី ដំណោះស្រាយទៅសិក្ខាកាមផ្ទៀងផ្ទាត់ | តូច | ៤០នាទី | ឯកសារចែក ទំព័រ១០-១១ |
| | | **សម្រាកអាហារថ្ងៃត្រង់** | | | |
| 13 | 14:00-14:10 | -រំលឹកមេរៀនកាលពីព្រឹក ដោយសួរសិក្ខាកាមថាតើព្រឹកមិញយើងរៀនពីអ្វីខ្លះ? | ធំ | ១០នាទី | |
| **បែបបទទី ៣: ការបង្រៀនភាសា សារសំខាន់នៃការនិយាយ** | | | | | |
| 14 | 14:10-14:20 | -អ្នកសម្របសម្រួលបិទបង្ហាញគោលបំណង : មាន ៣ ចំនុចក្នុងគោលបំណង | ធំ | ១០នាទី | ក្រដាសផ្ទាំងធំ |
| 15 | 14:50-15:00 | **សំណួរ** : តើមនុស្សយើងមានវិធីរៀនដូចគ្នាដែរឬទេ ?<br>- អ្នកសម្របសម្រួលកត់ត្រាចម្លើយសិក្ខាកាមលើក្តារខៀន | ធំ | ១០នាទី | |
| 16 | 15:00-15:30 | -ការលើកស្ទួយ "**ការនិយាយ**" ក្នុងថ្នាក់រៀន ហើយរៀបចំសំដែងតួរសកម្មភាព៣ ទាក់ទងការជំរុញសិស្សអោយប្រឹងនិយាយ ។ | តូច | ៣០នាទី | |
| **បែបបទទី ៤: ការបង្រៀនភាសា សារសំខាន់នៃអំណាន** | | | | | |
| 17 | 15:30-15:35 | -បិទបង្ហាញគោលបំណងមេរៀន | ធំ | ៥នាទី | ក្រដាសផ្ទាំង ធំ |
| 18 | 15:35-15:45 | -បង្ហាញសំណួរ: តើលោកគ្រូអ្នកគ្រូមានវិធីអ្វីខ្លះក្នុងការបង្រៀនអំណាន ?<br>-អ្នកសម្របសម្រួលធ្វើបញ្ជីយុទ្ធវិធីខ្លះៗជាមួយសិក្ខាកាម ដោយបិទរ៉ាមធំ ដើម្បីសរសេរចម្លើយរបស់សិក្ខាកាម | ធំ | ១០នាទី | |
| | 15:45-16:00 | **សម្រាក** | | ១៥នាទី | |
| 19 | 16:00-16:20 | **យុទ្ធវិធីមួយចំនួន ដើម្បីរៀបចំកម្មវិធីបំប៉នបន្ថែមស្តីពីអំណាន** :<br>១-**អំណានគ្មានស្រៈ**: បិទផ្ទាំងអត្ថបទត្រូវបំពេញលើក្តារខៀន<br>អ្នកសម្របសម្រួលចែកអត្ថបទអំណានថតចម្លងខុសៗគ្នាទៅអោយ សិក្ខាកាមធ្វើ ជាដៃគូរ ដំបូងអោយសិក្ខាកាមសរសេរឡើងវិញដោយ គ្មានស្រៈ រួចប្តូរគ្នាបំពេញស្រៈ | ដៃគូរ | ២០នាទី | |
| 20 | 16:20-16:40 | ២-**ការប្តូរព្យញ្ជនៈ**: បិទផ្ទាំងអត្ថបទមិនពេញលេញអោយប្តូរព្យញ្ជនៈ<br>**អ្នកសម្របសម្រួលចែកអត្ថបទអំណានថតចម្លងខុស ៗគ្នា ទៅអោយ** | ដៃគូរ | ២០នាទី | អត្ថបទ ថតចម្លង |

| | | | | | |
|---|---|---|---|---|---|
| | | **សិក្ខាកាមធ្វើ ជាដៃគូរ ដំបូងអោយសិក្ខាកាមសរសេរឡើងវិញ** ដោយផ្លាស់ប្តូរព្យញ្ជនៈ ២ តួរ ដូចជា ក ⟶ ខ ខ ⟶ ក រួចប្តូរ **គ្នាសរសេរឡើងវិញ រួចអាន។** | | | |
| 21 | 16:40-16:55 | ៣-**ល្បែងពាក្យ** ល្បែងបែបនេះអាចជួយកុមារអោយមានបំរុងប្រយត្ន័ក្នុងការសង្កេតពាក្យ និងវិធីសរសេរពាក្យ -អ្នកសម្របសម្រួលបង្ហាញឧទាហរណ៍ លោត ( *ល ោ ត* ) **បន្ទាប់មកអោយសិក្ខាកាមសរសេរបង្ហាញពាក្យ : *ផ្កាយ - ចុះ - ឡើង - ជិត - ខ្ពស់ - ទាប - ទៅ - មក*** | តូច | ២០នាទី | |
| 22 | 16:55-17:00 | សរុបមេរៀន វាយតម្លៃ និងសំណួមពរប្រចាំថ្ងៃ | | | |
| **ថ្ងៃទី ២** | | | | | |
| 23 | 7:30-7:40 | រំលឹកមេរៀនកាលពីម្សិលមិញ | ធំ | ១០នាទី | |
| 24 | 7:40-8:00 | ៤-**ការប្រើបំណ្ណ** អោយសិក្ខាកាមបង្ហាញពីវិធីបង្រៀនស្តីពីការបង្កើតពាក្យ -អ្នកសម្របសម្រួលបង្ហាញប័ណ្ណព្យញ្ជនៈ និងស្រៈ ទៅអោយសិក្ខាកាម រៀបចំបង្កើតពាក្យ -អ្នកសម្របសម្រួលចែកប័ណ្ណពាក្យ និងរូបភាព ទៅអោយសិក្ខាកាម តាមក្រុមផ្គូរផ្គង ពាក្យ ទៅនឹង រូប ។ | តូច | ២០នាទី | |
| បែបបទទី ៥: ការរៀនគណិតវិទ្យា | | | | | |
| 25 | 8:00-8:05 | -បិទបង្ហាញគោលបំណងចំនួន ២ | ៰ | ៥នាទី | ក្រដាស ផ្ទាំងធំ |
| 26 | 8:05-8:25 | **ក/សំណួរ** -ហេតុអ្វីបានជាកុមារមួយចំនួនជួបការលំបាកក្នុងការរៀនគណិតវិទ្យា ? - អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន **- អ្នកសម្របសម្រួលបិទតារាង ( ក ) អោយសិក្ខាកាមផ្ទៀងផ្ទាត់គំនិត និងពិភាក្សាពីបទពិសោធកន្លងមក និងបិទតារាងចម្លើយលើក្តារខៀន** | ធំ | ២០នាទី | បិទ៉ាមធំ តារាងចម្លើយ |
| 27 | 8:25-8:45 | -អ្នកសម្របសម្រួលចែកបញ្ជីសំណួរវាយតម្លៃផ្ទាល់ខ្លួន ស្តីពីវិធីបង្រៀនគណិតវិទ្យាតារាង ( ខ ) ទៅអោយសិក្ខាកាមម្នាក់ៗឆ្លើយ -អ្នកសម្របសម្រួលបូកសរុបចម្លើយ លើផ្ទាំងក្រដាសធំ | បុគ្គល | ២០នាទី | |
| | 8:45-9:00 | សម្រាក | | ១៥នាទី | |

| | | | | | |
|---|---|---|---|---|---|
| 28 | 9:00-10:0 | **ខ/ <u>ការអភិវឌ្ឍន៍ ការយល់ដឹងបញ្ញត្តិគណិតវិទ្យា</u>**<br>សួរសិក្ខាកាម តើមានវិធីអ្វីខ្លះក្នុងការបង្រៀនគណិតវិទ្យា ?<br>-អ្នកសម្របសម្រួលសរសេរសកម្មភាព ៤ ប្រភេទលើក្តារខៀន :<br>១-ការប្រើវត្ថុបី<br>២-ការប្រើសញ្ញា<br>៣-ការប្រើប្រាស់ភាសា<br>៤-ការប្រើប្រាស់រូបភាព<br>**-អ្នកសម្របសម្រួលពន្យល់ពីការផ្លាស់ប្តូរពីរូបីមកសញ្ញា ពីសញ្ញាមកភាសា ពី សញ្ញាមករូបភាព ។ល។**<br>ឧទាហរណ៍ : ចាន់ ថន.........<br>-អោយសិក្ខាកាមតាមក្រុមនីមួយៗតែងចំណោទមួយ ដោយផ្លាស់ប្តូរពីទម្រង់មួយទៅទម្រង់មួយទៀត ។<br>**ចំណាំ** :ពន្យល់សិក្ខាកាមថា សិស្សអាចផ្លាស់ប្តូរពីទម្រង់មួយទៅទម្រង់មួយទៀតបាន មានន័យថា សិស្សអាចយល់បាន （ ពាក់សូណូមី ） | ធំ/<br>តូច | ៦០នាទី | |
| 29 | 10:00-10:10 | **គ/ <u>បញ្ហាភាសាក្នុងគណិតវិទ្យា</u>**<br>**-អោយសិក្ខាកាមរកពាក្យគន្លឹះទាក់ទងទៅនឹងប្រមាណវិធី បូក -ដក គុណ - ចែក ។** | ធំ | ១០នាទី | |
| 30 | 10:10-10:30 | -សិក្ខាកាមបង្ហាញឧទហរណ៍ ជុំវិញពាក្យគន្លឹះ ។ | តូច | ២០នាទី | |
| | 10:30-10:45 | សម្រាក | | ១៥នាទី | |
| បែបបទទី ៦: ការវិភាគ និងឆ្លើយតបទៅនឹងកំហុសរបស់សិស្ស | | | | | |
| 31 | 10:45-10:50 | - បិទ និងពន្យល់គោលបំណង | ធំ | ៥នាទី | ផ្ទាំងក្រដាសធំ |
| 32 | 10:50-11:00 | **២-<u>ការវិភាគកំហុសសិស្ស</u>** : បង្ហាញ ឧទាហរណ៍ ទំព័រ ៤ ដោយសរសេរលើក្តារខៀន :<br>១៤៣     ១១៦     ២១<br>—២៨     — ៩៧     —១៣<br>១២៥     ១៨១     ១២<br>- អោយសិក្ខាកាមវិភាគកំហុស របស់សិស្សប្រភេទនេះ （ ដកលេខតូចពីលេខធំ និងគេមិនបានគិតតាមវិធីដកលេខ ） ។ | ធំ | ១០នាទី | |
| 33 | 11:00-11:30 | -ចែកករណីសិក្សាដែលបង្ហាញពីកំហុសរបស់សិស្សអោយគ្រប់សិក្ខាកាម<br>- អោយសិក្ខាកាមតាមក្រុម ពិភាក្សា ដោយវិភាគ និងពណ៌នាពីកំហុសរបស់សិស្ស ។ | តូច | ៣០នាទី | |

| | | | | | |
|---|---|---|---|---|---|
| 34 | 14:00-14:10 | រំលឹកមេរៀនទាក់ទងនឹងមេរៀនថ្មី | | ១០នាទី | |
| **បែបបទទី ៧៖ ការកសាងសម្ភារឧបទេសសម្រាប់បង្រៀនភាសាខ្មែរ** | | | | | |
| 35 | 14:10-17:00 | -គ្រូបង្ហាញពីរបៀបផលិតសម្ភារបង្រៀនមុខវិជ្ជាភាសាខ្មែរ ទំហំក្រដាសកាតុង របៀបប្រើប្រាស់ ក្នុងនោះមានតារាងដូចជា :<br>១-តារាងព្យៃកសូរ ២-ស្គាល់ន័យពាក្យ ៣-ទំរង់ពាក្យ ៤-អត្ថន័យពាក្យ<br>៥-ទីតាំងពាក្យ ៦-វិភាគល្បះ ៧-លំដាប់លំដោយហេតុការណ៍<br>៨-ការសរសេររៀបរាប់ ៩-ការប្រកបពាក្យ ១០-តែងល្បះ ១១-ពង្រីកល្បះ<br>១២-បណ្ណ័ព្យញ្ជនៈខ្មែរ ៣៣ តួរ ១៣-បណ្ណ័ស្រៈនិស្ស័យ២៧តួរ។ | តូច | ១៨០នាទី | |
| | | | | | |
| 36 | 7:30-9:00 | បន្តការកសាងសម្ភារឧបទេសសម្រាប់បង្រៀនភាសាខ្មែរ | | | |
| | 9:00-9:15 | **សម្រាក** | | ១៥នាទី | |
| **បែបបទទី ៨៖ ការកសាងសម្ភារឧបទេសសម្រាប់បង្រៀនគណិតវិទ្យា** | | | | | |
| 37 | 9:15-11:30 | -គ្រូបង្ហាញពីរបៀបផលិតសម្ភារបង្រៀនមុខវិជ្ជាគណិតវិទ្យា ទំហំក្រដាសកាតុង របៀបអ៊ុតប្លស្ទិច របៀបប្រើប្រាស់ ក្នុងនោះមានតារាងដូចជា :<br>១-តារាងប្រតិទិនប្រចាំខែ រឺឆ្នាំ ២-តារាងលំដាប់លេខ ៣-បន្ទះរាយ ដប់ រយ<br>៤-បណ្ណ័លេខខ្មែរ 0ដល់៩ លេខឡាតាំង 0ដល់ 9 ៥-បណ្ណ័សញ្ញា ធំជាង តូចជាង ស្មើ ប្រភាគ បូក ដក គុណ ចែក ៦-បណ្ណ័រូបជញ្ជីង<br>៧-បណ្ណ័រូបនាឡិកាមានទ្រនិចបង្វិលបាន ៨-តារាងផ្គូរផ្គងលក្ខណៈត្រលប់នៃវិធីគុណ ៩-តារាងក្រាប ១០-តារាងប្រៀបធៀបប្រភាគ។<br>-សិក្ខាកាមរៀបផលិតសម្ភារឧបទេសបង្រៀនគណិតវិទ្យា | ក្រុម តូច | ១៣០ នាទី | |
| | | **សម្រាកអាហារថ្ងៃត្រង់** | | | |
| 38 | 14:00-16:00 | បន្តការកសាងសម្ភារឧបទេសសម្រាប់បង្រៀនគណិតវិទ្យា | តូច | ១៥០ នាទី | |
| 39 | 16:00-17:00 | ពន្យល់ពីគោលការណ៍ រើសសិស្ស រើសគ្រូ និងដំណើរការរៀបចំការបំប៉នសិស្សរៀនយឺត។ | ធំ | ៦០នាទី | |
| | | | | | |

# បែបបទទី ១ ៖ ការរំលឹកឡើវិញ និង គោលការណ៍នៃការបំប៉នបន្ថែម

## I. គោលបំណង ៖

- សិក្ខាកាម រៀបរាប់អំពីការបង្រៀនថ្នាក់បំប៉នបន្ថែម ដោយសង្កត់ធ្ងន់ទៅលើសេចក្តីត្រូវការរបស់សិស្សម្នាក់ ៗ
- សិក្ខាកាម ពន្យល់គោលការណ៍ខ្លះៗ ដែលទាក់ទងទៅនឹងសកម្មភាពបំប៉នបន្ថែមដល់សិស្ស
- សិក្ខាកាម កំណត់គោលការណ៍មួយចំនួនដែលទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនជាក់ស្តែង ។

## II. រយៈពេល ៖ ២ ទៅ ៣ ម៉ោង ៖

## III. សម្ភារ ៖

- ក្រដាសផ្ទាំងធំ
- ប៊ិចហ្វឺត
- ស្កុត
- ឯកសារស្តីអំពីវិធីសាស្ត្របំប៉នបន្ថែម ។

## IV. លំនាំបង្រៀន ៖

ក. សេចក្តីផ្តើម ៖ អ្វីទៅដែលហៅថាការបង្រៀនបំប៉នបន្ថែម ?

- សួរសិក្ខាកាម "តើការបង្រៀនបំប៉នបន្ថែមមានលក្ខណៈយ៉ាងដូចម្តេច ?"
  - កត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តាខៀន
  - ការបង្រៀនមេរៀនម្តងទៀត
  - ជួយពន្យល់បន្ថែមដល់សិស្សមួយចំនួន
  - ជួយអោយសិស្សប្រឡងជាប់
  - បង្រៀនសិស្សមួយចំនួនក្រៅម៉ោងសិក្សា
  - ជួយដល់សិស្សតាមសេចក្តីត្រូវការរបស់គេម្នាក់ ៗ ។
- ចម្លើយទាំងអស់អាចមានភាពត្រឹមត្រូវខ្លះ ទោះបីជាយ៉ាងណាក៏ដោយ អ្នកសម្របសម្រួល គួរតែសង្កត់ធ្ងន់លើចម្លើយដែលនិយាយអំពីការជួយទៅតាមសេចក្តីត្រូវការរបស់សិស្សម្នាក់ ៗ ។ អ្នកសម្របសម្រួលពន្យល់សិក្ខាកាម

ថា ការបង្រៀនបំប៉នបន្ថែមមិនមែនជាការបង្រៀនតាមកម្មវិធីសិក្សាម្តងទៀតនោះទេ ។ ការបំប៉នបន្ថែម គឺជាការវាយតម្លៃលើសេចក្តីត្រូវការរៀនសូត្ររបស់សិស្សម្នាក់ ។ ការវាយតម្លៃនេះ ជាជំនួយសម្រេចដល់សិស្សទទួលបាន ជោគជ័យក្នុងបំណិនដែលកំណត់ដោយកម្មវិធីសិក្សា ។

- គ្រូមួយចំនួនយល់ច្រឡំថា ការបំប៉នបន្ថែមសង្កត់ធ្ងន់លើអ្វី ៗ ដែលសិស្សមិនអាចធ្វើបាន ជាជាងគិតដល់អ្វី ៗ ដែលសិស្សអាចធ្វើបានខ្លះ ៗ ។ ពន្យល់ដល់សិក្ខាកាមថាសេចក្តីត្រូវការពិសេសលើការអប់រំមានចំណុច ២ យ៉ាង :
    - ក/ សេចក្តីត្រូវការពិសេស ដែលទាក់ទងទៅនឹងចំណាប់អារម្មណ៍និងសមត្ថភាពរបស់សិស្សដែលមានស្រាប់ ។
    - ខ/ សេចក្តីត្រូវការពិសេស ដែលទាក់ទងទៅនឹងបញ្ហាដែលសិស្សមានក្នុងថ្នាក់រៀន ។
- ជាញឹកញាប់គ្រូបង្រៀនក្នុងថ្នាក់បំប៉នបន្ថែមគេគិតតែចំណុច " ខ " ខាងលើតែប៉ុណ្ណោះ ។ បញ្ហានេះនាំអោយយល់ច្រឡំនិងមានភាពលំអៀងក្នុងការបង្រៀនដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការពិសេសរបស់សិស្ស ។ បិទដ្យាក្រាមដូចខាងក្រោមលើក្តាខៀន ។




- ដ្យាក្រាមនេះបញ្ជាក់ថា គ្រូត្រូវតែគិតដល់ចំណុចទាំងពីរខាងលើ ។ ប្រសិនបើគ្រូគ្រាន់តែគិតដល់អ្វី ៗ ដែលសិស្សធ្វើមិនបានទេនោះគ្រូជាអ្នកធ្វើអោយសិស្សធ្លាក់ទឹកចិត្តដោយមើលស្រាលដល់សមត្ថភាពរបស់សិស្សនោះ ។ បញ្ហានេះបណ្តាលអោយសិស្សមិនចង់រៀនផងដែរ ។
- គ្រូត្រូវតែរកអោយឃើញនូវចំណុចខ្លាំងរបស់សិស្សក្នុងការសិក្សា ហើយប្រើចំណុចខ្លាំងទាំងនេះ ដើម្បីពង្រឹងការរៀនសូត្ររបស់គេ ។ អោយសិក្ខាកាមអានករណីសិក្សាខាងក្រោម រួចកំណត់វិធីបំប៉នបន្ថែមដែលគិតពីចំណុចខ្លាំង និង ចំណាប់អារម្មណ៍របស់សិស្ស ។

### ករណីសិក្សា

ចាន់ថាជាក្មេងប្រុសម្នាក់រៀននៅថ្នាក់ទី ១ គេជាក្មេងដែលខ្លាចគ្រូ ។ ពេលដែលគ្រូអោយចាន់ថា អាន ឬ សរសេរ គេខ្លាចហើយនៅស្ងាត់ស្ងៀម ។ ប៉ុន្តែមានមេរៀនខ្លះ លោកគ្រូសង្កេតឃើញថា ចាន់ថា សប្បាយចិត្តក្នុងការសិក្សាជាមួយមិត្តភក្តិ និង ចូលរួមយ៉ាងសកម្មក្នុងការងារក្រុមតូច ។ លោកគ្រូសង្កេតឃើញទៀតថា ចាន់ថា ចូលចិត្តគូរគំនូរ និង ពូកែគូរគំនូរ ។ ក៏ប៉ុន្តែគេមានបញ្ហាក្នុងការអាន និង សរសេរ ។ ដូច្នេះលោកគ្រូបានរៀបចំសកម្មភាព អំណាន និង សំណេរអោយចាន់ថាធ្វើការជាមួយមិត្តរបស់គេ ហើយបញ្ចូលសកម្មភាពគូរគំនូរទៀតផង ។ ឧទាហរណ៍ : នៅពេលមានតែងសេចក្តី គ្រូអោយ ចាន់ថា គូរអំពីអ្វី ៗ ដែលគេបានឃើញកាលពីម្សិលមិញ ។ លោកគ្រូអោយគេសរសេរឃ្លា ២ ឬ ៣ ល្បះអំពីអ្វី ៗ ដែលមានក្នុងរូបភាពនោះ ។

- ក្រោយពីអានករណីសិក្សា អោយសិក្ខាកាមឆ្លើយសំណួរជាក្រុមតូច អោយបាន ៣០ នាទី សម្រាប់លំហាត់នេះ ។
  - តើអ្វីជាតម្រូវការពិសេសរបស់ចាន់ថា ?
  - តើអ្វីជាចំណាប់អារម្មណ៍ពិសេសរបស់ចាន់ថា ?
  - ក្នុងសកម្មភាពអ្វីខ្លះ ដែលទទួលបានជោគជ័យ ?
  - តើគ្រូបានជួយចាន់ថាបានយ៉ាងដូចម្តេច ?
  - ក្នុងការជួយដល់ចាន់ថា តើគ្រូបានគិតដល់តម្រូវការ " គោលការណ៍មូលដ្ឋាននៃការបំប៉នបន្ថែម " និងចំណាប់អារម្មណ៍របស់គេដែរឬទេ ?

## ខ. គោលការណ៍នានានៃការបំប៉នបន្ថែម :

រំលឹកឡើងវិញអំពីវិធីផ្សេង ៗ ក្នុងការបំប៉នបន្ថែម ។ ចែកឯកសារដល់សិក្ខាកាម នឹង ពិភាក្សាជាក្រុមធំ ។

## គោលការណ៍មូលដ្ឋាននៃការបំប៉នបន្ថែម

1. ពិនិត្យមើលថា សិស្សយល់ច្បាស់អំពីគោលបំណងនៃការរៀននិង មានរបៀបតាមដានការសិក្សារបស់គេក្នុងការឈានទៅសំរេចគោលបំណងនេះ ។ ការយល់ដឹងនេះ នាំអោយសិស្សទទួលខុសត្រូវចំពោះការរៀនរបស់ខ្លួន ។
2. ជួយសិស្សដោយប្រើវិញ្ញាណផ្សេង ៗ រួមមាន ÷
   - ការមើល （ឧទាហរណ៍ : គូរគំនូរ）
   - បង្ហាញរូបភាព
   - ការស្តាប់ （ឧទាហរណ៍ : ចំរៀង តារាងមេលេខ）
   - ការប្រើសម្ភារឧបទេស ( ឧ . ប័ណ្ណអក្សរ ប័ណ្ណពាក្យ )
   - ល្បែងសិក្សា ល្ខោនត្រាប់ កាយសិក្សា . . . ។

   វិធីនេះជួយពង្រឹងបន្ថែមលើចំណេះដឹងមានស្រាប់របស់សិស្សកន្លងមក ។ ម្យ៉ាងទៀតនាំអោយសិស្សមានទំនុកចិត្តនិងជឿជាក់លើខ្លួនឯងទៀតផង ។ ការបំប៉នបន្ថែមទាមទារអោយគ្រូយល់ពីវិញ្ញាណទាំង ៥ របស់សិស្សហើយគ្រូត្រូវដឹងថាសិស្សរបស់គាត់ខ្សោយវិញ្ញាណណាខ្លះ ។
3. រៀបចំការបង្រៀនជាជំហានតូច១ កុំផ្តល់ខ្លឹមសារច្រើនពេក ដែលសិស្សមិនអាចយល់បាន ។
4. ការយកចិត្តទុកដាក់លើការយល់ដឹងរបស់សិស្សប្រសើរជាងការបង្រៀនដែលរត់តាមកម្មវិធី ។
5. បង្កើតសកម្មភាពដែលជួយអោយសិស្សដឹងភ្លាម១ តើគេមានការយល់ដឹងឬទេ ? （ឧទាហរណ៍ : អោយសិស្សយកខ្លឹមសារទៅអនុវត្តជាក្រុមតូច ៗ នូវអ្វីដែលបានរៀនជាក្រុមធំ） ។
6. ត្រូវតែមានការវាយតម្លៃញឹកញាប់ដើម្បីជួយគ្រូរៀបចំការបង្រៀនដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សិស្ស ។
7. ជួយបង្រៀនដល់សិស្សម្នាក់១ ក្រោយពីបានធ្វើការវិភាគកំហុសរបស់សិស្សម្នាក់១ រួច ។ អាចមានការលំបាកពេលដែលមានសិស្សច្រើនជាង ១០ នាក់ក្នុងក្រុមតូច ។ ប៉ុន្តែប្រសិនជាមានការត្រួតពិនិត្យយ៉ាងជិតដល់លើការងាររបស់សិស្សក្នុងក្រុមតូច ១ នាំអោយគ្រូមានលទ្ធភាពជួយដល់សិស្សតាមតម្រូវការរៀនសូត្ររបស់គេ ។
8. កុំអោយមានសិស្សចំនួនច្រើនពេកក្នុងក្រុមតូចនាំអោយមានបញ្ហា សម្រាប់គ្រូពេលដែលគាត់ចង់ជួយដល់សិស្សម្នាក់ ១ ។ ថ្នាក់ដែលមានសិស្សច្រើនដូចថ្នាក់ធម្មតាមិនលើកទឹកចិត្ត ឬ ជំរុញអោយសិស្សចង់រៀនទេ ។

**9 .** ខ្លឹមសារបង្រៀនត្រូវមានទំនាក់ទំនងទៅនឹងជីវិតប្រចាំថ្ងៃរបស់សិស្ស ជាញឹកញាប់សិស្សរៀនអំពីប្រធានបទក្នុងថ្នាក់រៀនដែលមិនមានទំនាក់ទំនងជាមួយជីវិតប្រចាំថ្ងៃរបស់សិស្ស ។ ពេលខ្លះគ្រូប្រើភាសាស្មុគស្មាញ ជួនកាលពាក្យខ្លះក្នុងសៀវភៅសិក្សាក៏មានភាពស្មុគស្មាញ សម្រាប់សិស្សស្តាប់នោះដែរ ។ សកម្មភាពរៀនដែលសមស្របតាមជីវិតជាក់ស្តែងរបស់សិស្ស អាចរួមបញ្ចូលមានល្បែងសិក្សាការធ្វើគ្រាប់ និង សម្តែងតួ ។

- ក្រោយពីអានគោលកាណ៏ទាំង ៩ នៃការបំប៉នបន្ថែម ចូរធ្វើលំហាត់ផ្គូផ្គងរវាងគោលការណ៏ទាំងនេះទៅនឹងករណីសិក្សាខាងក្រោមនេះ ។ ក្រុមនីមួយ ៗ ត្រូវតែសរសេរលេខនៃគោលការណ៏នៅខាងមុខនៃករណីសិក្សានីមួយៗ ។ មានចម្លើយជាឧទាហរណ៏ក្នុងវង់ក្រចក ។

## ករណីសិក្សា

----ក. លោកគ្រូប្រាប់សិស្សថាថ្ងៃនេះយើង អាន និង សរសេរពាក្យថ្មី ចំនួន ៥ ។ នៅចុងបញ្ចប់មេរៀនសិស្សសរសេរពាក្យថ្មី ៧ ក្នុងសៀវភៅហើយ វាយការណ៍ចំនួនពាក្យដែលគេបានសរសេរត្រឹមត្រូវពេលដែលគេបានធ្វើលំហាត់ ។ ( ១ . ៣ . ៥ )

----ខ. លោកគ្រូលើកប័ណ្ណព្យញ្ជនៈ ៥ អោយសិស្សមើល ហើយអោយសិស្សផ្គូផ្គងប័ណ្ណព្យញ្ជនៈនោះជាមួយប័ណ្ណរូបភាពដែលមានសម្លេងដើមដូចគ្នា ។ ( ២ . ៥ )

----គ. ក្រោយពីបានរៀនពាក្យថ្មី ៧ លោកគ្រូអោយសិស្សធ្វើលំហាត់ដោយច្រៀង ។( ២ )

----ឃ. ក្រោយពីបង្រៀនលេខបូកលោកគ្រូអោយសិស្សឈរជាក្រុមដែលបង្ហាញអំពីល្បះបូក ។(២.៥ )

----ង. លោកគ្រូសួរសំណួរខ្លីៗ អោយសិស្សឆ្លើយក្រោយពីបង្រៀន ២ ម៉ោង ដើម្បីត្រួតពិនិត្យការយល់ដឹងរបស់សិស្ស ។( ៦ )

----ច. លោកគ្រូសំរេចចិត្តបង្រៀនបន្ថែមមួយថ្ងៃទៀត សម្រាប់មេរៀនអំពីការដកលេខ ពីព្រោះគាត់សង្កេតឃើញថាសិស្សជាច្រើនមិនទាន់យល់ច្បាស់ ។ ( ៤.៦ )

----ឆ. ក្នុងការបង្រៀនវិធីដកលេខ លោកគ្រូឃើញថា វិទ្ធ អត់យល់អំពីវិធីដកលេខ ដែលត្រូវដកពីលើចុះក្រោម ។ ដូច្នេះលោកគ្រូបានរៀបចំសម្ភារ ដូចជា បំពង់បឺតជាជំនួយក្នុងការដកលេខ ។( ៧)

----ជ. លោកគ្រូឃើញថាសិស្សម្នាក់ច្រឡំប្រមាណវិធីបូក និង ប្រមាណវិធីដក ដូច្នេះលោកគ្រូសរសេរចំណោទប្រមាណវិធីបូក ជាពណ៌មួយ ហើយប្រមាណវិធីដក ជាពណ៌ផ្សេងទៀត ។ ( ២ . ៧ )

----ឈ. លោកគ្រូរៀបចំផ្សារប្រឌិតក្នុងបន្ទប់រៀនរបស់គាត់ ។ សិស្សមួយចំនួនកាន់ប័ណ្ណក្រដាសប្រាក់សិប្បនិម្មិត សិស្សមួយចំនួនទៀតធ្វើជាអ្នកលក់របស់ផ្សេងៗ ។របស់ទាំងនេះត្រូវបានបង្ហាញជាប័ណ្ណរូបភាពមាន សាប៊ូ ខោអាវ មុខម្ហូប ។ល ។ពេលដែលសិស្សលក់ ឬ ក៏ទិញវាត្រូវតែចេះអាប់លុយ ។( ២.៧ )

## មេរៀនទី ២ : កត្តាដែលនាំអោយសិស្សជួបបញ្ហាក្នុងការរៀន

**II. គោលបំណង :**

- សិក្ខាកាម រៀបរាប់អំពីកត្តាផ្សេង ៗ ដែលប៉ះពាល់ដល់ការរៀនសូត្រ
- សិក្ខាកាម ធ្វើចំណាត់ថ្នាក់នៃកត្តាទាំងនោះបានត្រឹមត្រូវ
- សិក្ខាកាម កំណត់មូលហេតុផ្សេង ៗ ដែលនាំអោយមានបញ្ហាមួយចំនួន
- សិក្ខាកាម កំណត់វិធីផ្សេង ៗ ដើម្បីដោះស្រាយ ឬ ចៀសវាងបញ្ហាក្នុងការរៀន ។

**O រយៈពេល : ៣ ម៉ោង :**

**V. សម្ភារ :**

- ក្រដាសផ្ទាំងធំ
- ប៊ិចហ្វឺត
- ស្កុត
- ដ្យាក្រាមផ្សេង ៗ
- ឯកសាររៀបរាប់អំពីសញ្ញានៃបញ្ហាដែលសិស្សអាចមាន
- ឯកសារដែលរៀបរាប់អំពីវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហា ។

**VI. លំនាំបង្រៀន :**

**ក. កត្តាដែលមានឥទ្ធិពលលើការរៀនរបស់សិស្ស :**

- អ្នកសម្របសម្រួល សង្ខេបប្រភេទកត្តាដែលនាំអោយសិស្សជួបបញ្ហាក្នុងការរៀន ។ មានកត្តាបីប្រភេទសំខាន់ៗ ដែលមានឥទ្ធិពលលើការរៀនរបស់សិស្ស ។ សរសេរកត្តាទាំងនេះលើក្តារខៀន ។

  + កត្តាផ្ទាល់ខ្លួនរបស់សិស្ស ( ឧ . ពិការភ្នែក . . . )

  + អាកប្បកិរិយា និង ចំណាប់អារម្មណ៍របស់សិស្សអោយចង់រៀន

  + ស្ថានភាពនៅផ្ទះ និង ក្រុមគ្រួសារ ។

- ពន្យល់ដល់សិក្ខាកាមថា  កត្តាទី ១ និង កត្តាទី ២ ខាងលើនេះ  ជះឥទ្ធិពលផ្ទាល់លើការរៀនសូត្ររបស់សិស្ស ។ កត្តាទី ៣ ដែលទាក់ទងទៅនឹងស្ថានភាពនៅផ្ទះអាចបង្កអោយមានបញ្ហាផ្លូវចិត្ត និង អាកប្បកិរិយាដែលប៉ះពាល់ដល់ការរៀនសូត្រ  ។ បញ្ហាផ្លូវចិត្ត និង អាកប្បកិរិយាអាចប៉ះពាល់រវាងសិស្ស និង សិស្ស ឬ សិស្ស និង គ្រូ ។
- កត្តាផ្ទាល់ខ្លួនរបស់សិស្សអាចជាបញ្ហាវិញ្ញាណ ឬ បញ្ហាពិការដែលប៉ះពាល់ដល់ការរៀន  ។  ពេលដែលគ្រូគិតដល់សិស្សដែលមានបញ្ហា ហើយរកឃើញដំណោះស្រាយសិស្សនេះអាចរៀនបានល្អដូចសិស្សឯទៀត ។ បញ្ហាវិញ្ញាណអាចជាបញ្ហានៃការឃើញ ឬ ការស្តាប់ ឬ ការនិយាយ ។ បញ្ហាទាំងនេះអាចមានសញ្ញាដែលគ្រូអាចដឹងបានប្រសិនបើយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន ។
- សញ្ញាចក្ខុវិញ្ញាណខ្សោយ
  1. ញីភ្នែកជាញឹកញាប់
  2. បិទភ្នែក បាំងភ្នែកដោយដៃ
  3. ពន្លឺប៉ះពាល់ភ្នែក
  4. ស្រលៀងភ្នែក ពព្រិច បើកភ្នែកប្រិម ៗ ពេលដែលអាន  ឬ សរសេរ
  5. កាន់សៀវភៅនៅជិតមុខ ឬ នៅឆ្ងាយមុខ
  6. ឈឺភ្នែក រមាស់ភ្នែក
  7. ប្រាប់ថាការមើលឃើញព្រិល ៗ
  8. សរសេរពាក្យ ឬ លេខបញ្ច្រាស
  9. ច្រឡំអក្សរ ដែលមានទ្រង់ទ្រាយស្រដៀងគ្នា  ។
- សញ្ញាសោតវិញ្ញាណខ្សោយ :
  1. ពេលដែលគ្រូនិយាយសិស្សផ្ទៀងត្រចៀកមួយចំហៀងស្តាប់
  2. មិនយកចិត្តទុកដាក់ស្តាប់គ្រូបង្រៀនក្នុងមេរៀនវ៉ាយវ៉ាប់ដូចជាស្តាប់មិនឮ
  3. ពេលសួរសំណួរសិស្សមិនឆ្លើយតប
  4. លំបាកធ្វើតាមការណែនាំរបស់គ្រូជាញឹកញាប់
  5. ការនិយាយមានលក្ខណៈចំឡែកដូចជាសម្លេងគ្រលួច
  6. និយាយឡូល ៗ ជាប់គ្នារដឹក
  7. រង់ចាំអោយមិត្តក្នុងថ្នាក់ពន្យល់ការណែនាំបន្ថែមលើការពន្យល់របស់គ្រូ
  8. មើលមុខរបស់អ្នកនិយាយ ជាពិសេសមាត់ និង បបូរមាត់
  9. ការនិយាយមានកំហុស ( សម្លេង)

10. ជាញឹកញាប់វាថា " សុំទោស" "អ៊ឺ" ។ល ។

- សញ្ញាការនិយាយខ្សោយ
  1. ប្រើឃ្លាមិនពេញ មិនអស់ន័យ (ឃ្លាស្ដាប់មិនបាន)
  2. វាក្យស័ព្ទមានធ្វើកាយវិការដោយគ្មាននិយាយដើម្បីធ្វើទំនាក់ទំនង ។
  3. និយាយតិចតួច មិនស្ទាត់ក្នុងការបញ្ចេញគំនិតយោបល់ និយាយច្រំដែល ៗ
  4. អត់សូវនិយាយ
  5. និយាយជាប់ ៗ ឬ ត្រដិត
  6. ការនិយាយមិនចេះលើកដាក់សម្លេង
  7. ដកដង្ហើមមិនធម្មតា ។
- កុំផ្ដល់សញ្ញាបញ្ហានីមួយ ៗ ខាងលើ អោយសិក្ខាកាមមើល ។ ត្រូវសរសេរលើប័ណ្ណជាចម្រុះហើយអោយសិក្ខាកាមធ្វើចំណាត់ថ្នាក់តាមប្រភេទបញ្ហា ។ ធ្វើលំហាត់នេះជាក្រុមតូច ៗ ។
- កត្តាដែលទាក់ទងទៅនឹងអាកប្បកិរិយា និង ចំណាប់អារម្មណ៍របស់សិស្សអាចជះឥទ្ធិពលលើការរៀនសូត្រ ។ មូលហេតុសំខាន់មួយដែលនាំអោយសិស្សមិនចង់រៀនគឺ បញ្ហាបរាជ័យ ដែលនាំអោយសិស្សមិនមានជំនឿលើខ្លួនឯង ។ អ្នកសម្របសម្រួលបិទដ្យាក្រាមខាងក្រោមលើក្ដារខៀនដើម្បីពន្យល់គំនិតនេះ ÷

**សូមពិចារណា**

តើអ្នកចូលចិត្តធ្វើសកម្មភាពដែលអ្នកមិនសូវពូកែដែរឬទេ ?

តើដ្យាក្រាមនេះបញ្ជាក់ពីអារម្មណ៍របស់អ្នករៀនយ៉ាងដូចម្ដេច ?

សូមពិភាក្សា



- អ្នករៀនមានអារម្មណ៍មិនទុកចិត្តខ្លួនឯង (ដែលបានកើតឡើង) ដោយសារបញ្ហាបរាជ័យក្នុងការសិក្សានាំអោយប៉ះពាល់សេចក្តីប្រាថ្នាចង់រៀនរបស់គេ ហើយបណ្តាលអោយមានបញ្ហាបរាជ័យក្នុងការសិក្សាបន្ថែមទៀតនៅពេលខាងមុខ ។
- ពេលខ្លះគ្រូរួមចំណែកធ្វើអោយសិស្សមានអារម្មណ៍អវិជ្ជមាន អោយសិស្សគ្មានទំនុកចិត្តលើខ្លួនឯងព្រោះគាត់មិនបានគិតដល់ចរិយាសម្បត្តិ និង ការគោរពសិស្សឡើយ ។ តើអ្នកធ្លាប់ប្រើពាក្យ " សិស្សខ្សោយ " នៅមុខសិស្សនេះដែរឬទេ ? សួរសិក្ខាកាម តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចបើឮអ្នកសម្របសម្រួលសន្ទនាគ្នា និង និយាយ ថា " សិក្ខាកាមទាំងអស់ខ្សោយណាស់ " ។ ជាការពិតសិក្ខាកាមមានអារម្មណ៍អាក់អន់ចិត្ត និង មិនមានទំនុកចិត្តលើខ្លួនឯង ។ គ្រូខ្លះមានទម្លាប់បែបនេះ ប៉ុន្តែគេត្រូវតែចៀសវាងការប្រើពាក្យនោះចំពោះមុខសិស្ស ។
- ស្ថានភាពនៅផ្ទះអាចប៉ះពាល់ ការរៀនសូត្ររបស់សិស្សដោយប្រយោល ដែលបណ្តាលអោយមានអាកប្បកិរិយាមិនសមរម្យទៅនឹងការរៀនសូត្រ ។

  ឧទាហរណ៍ : ប្រសិនបើឪពុកម្តាយមានការឈ្លោះគ្នាក្នុងផ្ទះ សិស្សអាចមានភាពអន់ចិត្តខ្លួនឯង ហើយធ្លាក់ទឹកចិត្ត រវើរវាយគេអាចមានទម្លាប់បង្កើតការឈ្លោះគ្នាក្នុងបន្ទប់រៀន ។ អាកប្បកិរិយាបែបនេះនាំអោយសិស្សជួបបញ្ហាក្នុងការចូលរួមសកម្មភាពសិក្សាតាមក្រុមធំ ឬ ក្រុមតូច ៗ ។

**ខ. ដំណោះស្រាយចំពោះកត្តាដែលនាំអោយសិស្សជួបបញ្ហាក្នុងការរៀន :**

- ទោះបីជាគ្រូមិនអាចដោះស្រាយបញ្ហានេះបាន ១០០% គ្រូអាចជួយដោះស្រាយខ្លះៗ ដែរ ។ ឧទាហរណ៍ : ប្រសិនជាសិស្សជួបការលំបាកក្នុងការរៀនដោយសារបញ្ហាពិការ គ្រូអាចផ្តល់ជំនួយឧបត្ថម្ភដើម្បីជួយកាត់បន្ថយការលំបាកក្នុងការរៀនសូត្ររបស់សិស្សពិការនោះ ។
- ម្យ៉ាងទៀត គ្រូត្រូវតែព្យាយាមជំរុញអោយសិស្សមានឥរិយាបថវិជ្ជមានក្នុងការរៀន ដោយគ្រូគិតដល់ចរិយាសម្បត្តិរបស់សិស្ស ដើម្បីចៀសវាងឥរិយាបថអវិជ្ជមាន ។
- គ្រូពុំសូវមានឥទ្ធិពលលើស្ថានភាពនៅផ្ទះ ។ ប្រហែលជាគ្មាននរណានៅផ្ទះសម្រាប់ជួយគាំទ្រសិស្សក្នុងការរៀន ឬក៏អាចមានការឈ្លោះគ្នាដែលបណ្តាលអោយមានការនឿយណាយក្នុងការងារសិក្សារបស់សិស្សនោះ ។ គ្រូគួរតែរកមធ្យោបាយដើម្បីអោយឪពុកម្តាយចូលរួមគាំទ្រថ្នាក់បំប៉នបន្ថែម ។

  ឧទាហរណ៍ : ការរៀបចំថ្នាក់បំប៉នបន្ថែមនៅតាមភូមិងាយស្រួលសម្រាប់ឪពុកម្តាយមើលឃើញការសិក្សាររបស់កូនខ្លួន ។ គ្រូអាចកំណត់ថ្ងៃពិសេស ១ ដង ក្នុង ១ ខែ អញ្ជើញឪពុកម្តាយមកមើលកូនរបស់គេរៀន ។ រៀបចំថ្នាក់បំប៉នបន្ថែមស្ថិតនៅភូមិងាយស្រួលសម្រាប់ឪពុកម្តាយទៅដល់អត់ចំណាយពេលវេលាច្រើនក្នុងការធ្វើដំណើរ ។
- បញ្ជីខាងក្រោមនេះបានផ្តល់គំនិតយោបល់ខ្លះ ៗ ដើម្បីដោះស្រាយបញ្ហាខាងលើ ។ អ្នកសម្របសម្រួលចែកចាយបញ្ជីនេះអោយសិក្ខាកាមអាន ។

**ដំណោះស្រាយចំពោះបញ្ហាចក្ខុវិញ្ញាណខ្សោយ :**

1. ប្រាប់អ្នកចាត់ការកម្មវិធីដែលអាចនាំសិស្សទៅទទួលវ៉ែនតា និង ការព្យាបាលភ្នែក
2. អោយសិស្សអង្គុយនៅកន្លែងដែលមានពន្លឺភ្លឺច្បាស់
3. កុំអោយមានពន្លឺព្រះអាទិត្យចាំងលើក្តារខៀន
4. អោយសិស្សអង្គុយជិតក្តារខៀន
5. តាមតែអាចធ្វើទៅបាន ផ្តល់ឯកសារដែលមានអក្សរធំ ៗ អោយសិស្ស
6. សរសេរពាក្យខ្លះសំខាន់ ៗ ជាពណ៌ពិសេសងាយស្រួលមើល ។

**ដំណោះស្រាយចំពោះបញ្ហាសោតវិញ្ញាណ**

1. ប្រាប់អ្នកចាត់ការកម្មវិធីដែលអាចនាំសិស្សទៅទទួលឧបករណ៍បំពងសម្លេងដល់សិស្សថ្លង់
2. ពេលដែលគ្រូនិយាយជាមួយសិស្ស ដែលមានបញ្ហាសោតវិញ្ញាណ ឃ្លាំមើលភ្នែករបស់សិស្ស ជាពិសេសពេលដែលគ្រូផ្តល់ការណែនាំ ឬ ការពន្យល់សំខាន់ ៗ ។
3. និយាយតាមធម្មតា កុំផ្លាស់ប្តូរសម្លេង ឬ ចលនាមាត់
4. ពេលបង្រៀនឈរនៅកន្លែងមានពន្លឺងាយស្រួលមើលមុខ ។ កុំឈរនៅកន្លែងដែលមានភ្លើង ឬ បង្អួចពីក្រោយ ពីព្រោះសិស្សចាំងភ្នែក ។
5. បើមានក្រុមតូច ៗ ជាច្រើនក្នុងថ្នាក់ អោយសិស្សដែលមានបញ្ហាសោតវិញ្ញាណអង្គុយនៅខាងមុខងាយស្រួលអោយវាវិលជុំវិញ ហើយនិងមើលមុខអ្នកនិយាយ ។
6. សរសេរពាក្យ និង ឃ្លាសំខាន់ ៗ លើក្តារខៀន ដែលអាចធ្វើទៅបាន ។

**ដំណោះស្រាយចំពោះបញ្ហាការនិយាយខ្សោយ**

1. ព្យាយាមយល់របៀបដែលសិស្សកំពុងនិយាយ ហើយនិងធ្វើការជួយវាកែចំណុចនិយាយខ្សោយនោះ
2. កុំអោយសិស្សផ្សេង ៗ សើចចំអក
3. ស្តាប់វាដោយមានអំណត់ ។ កុំកាត់សម្តីនិយាយរបស់សិស្សនោះ ។ អោយវានិយាយបានពេញលេញ មុននិងឆ្លើយតប ។ សិស្សនេះត្រូវតែរៀនទម្លាប់និយាយជាឃ្លាពេញលេញ ។
4. ព្យាយាមយល់អំពីបញ្ហារបស់សិស្ស ហើយនិងជួយគាំទ្ររកដំណោះស្រាយនេះ ។ សំខាន់ណាស់យើងត្រូវចងចាំថាបញ្ហានិយាយច្រើនចេញពីបញ្ហាផ្លូវចិត្ត ។
5. ដូច្នេះការជួយគាំទ្ររបស់គ្រូដែលមានលក្ខណៈស្និទ្ធស្នាលកុមារមេត្រីអាចជួយសិស្សដោះស្រាយបញ្ហានេះបាន ។

## ដំណោះស្រាយចំពោះបញ្ហាឥរិយាបថ និង ចំណាប់អារម្មណ៍ក្នុងការរៀន

1. រៀបចំសកម្មភាពដោយគិតដល់ការជោគជ័យ និង ចំណាប់អារម្មណ៏របស់សិស្ស ។ ដូច្នេះគ្រូត្រូវស្វែងយល់អំពីចំណាប់អារម្មណ៏របស់សិស្សហើយនិងបង្កើតសកម្មភាពអោយស្របទៅតាមចំណាប់អារម្មណ៏ទាំងនេះ ។ ធ្វើដូចនេះអាចទាមទារអោយគ្រូបកស្រាយមេរៀនដោយគិតវិញ្ញាណខ្លាំងរបស់សិស្ស ( ការមើល . ការស្តាប់ ឬ សកម្មភាពដែលមានចលនាកាយ និង ខាងផ្លូវចិត្ត ) ។ គ្រូត្រូវតែសង្កេតមើលយ៉ាងប្រុងប្រយ័ត្នអំពីវិធីរៀន របស់សិស្សម្នាក់ៗ ។
2. បង្កើតសកម្មភាពរៀន ដែលមានគោលបំណង នឹង អត្ថន័យច្បាស់លាស់ ។ សកម្មភាពជាច្រើនមិនសូវមានគោលបំណង ឬ អត្ថន័យដែលសមស្របទៅនឹងសេចក្តីត្រូវការ និង ជីវិតរស់នៅរបស់សិស្សម្នាក់ ៗ នោះទេ ។ គ្រូគួរតែរៀបចំសកម្មភាពជាល្បែងដែលមានគោលបំណងច្បាស់លាស់ ។ ( ឧទាហរណ៏ : អោយសិស្សដើរតួស្រាវជ្រាវក្រៅសាលារៀន នឹង ហាត់អានអ្វី ៗ ដែលសិស្សអាចរកបាន ដូចជា កាសែត ទស្សនាវដ្តី ផ្លាកសញ្ញា កញ្ចប់ផ្សេងៗ ) ។
3. រៀបចំថ្នាក់បំប៉នបន្ថែមនៅផ្ទះប្រសើរជាងការរៀបចំនៅសាលារៀនដែលនាំអោយសិស្សអៀនខ្មាស ជាពិសេសសិស្សធំ ៗ ។
4. គិតដល់សតិអារម្មណ៏របស់សិស្ស ។ កុំប្រើពាក្យ ដូចជា ខ្សោយ ល្ងើ មនុស្សភ្លើ ល្ងង់ខ្លៅ . . . ។

## ដំណោះស្រាយចំពោះបញ្ហាដែលកើតមានឡើងដោយសារស្ថានភាពនៅផ្ទះ

1. ដាក់សិស្សដែលមានបញ្ហាក្នុងក្រុមតូចជាមួយសិស្សស្លូតរាក់ទាក់រួសរាយ
2. ព្យាយាមជួបជាមួយឳពុកម្តាយដើម្បីយល់អំពីស្ថានភាពនៅផ្ទះ
3. អញ្ជើញឳពុកម្តាយមកមើលកូនរបស់គាត់រៀននៅថ្នាក់បំប៉នបន្ថែម ។

# មេរៀនទី ៣ : ការបង្រៀនភាសា : សារសំខាន់នៃការនិយាយ

## I. គោលបំណង

- សិក្ខាកាម ពន្យល់បានថា វិធីបង្រៀនសិស្សអោយចេះនិយាយអំពីគំនិតយោបល់របស់គេអាចពង្រឹងបន្ថែមដល់ការរៀនសូត្រ
- សិក្ខាកាម ពិពណ៌នាយុទ្ធវិធី សម្រាប់ពង្រឹងសមត្ថភាពនិយាយរបស់កុមារ
- សិក្ខាកាម ប្រើយុទ្ធវិធីផ្សេង ៗ ក្នុងថ្នាក់បំប៉នបន្ថែម ។

## II. រយៈពេល

៣ ទៅ ៤ ម៉ោង

## III. សម្ភារ

- ក្រដាសសផ្ទាំងធំ
- ហ្វឺត
- ស្កុត
- ល្បែងផ្សេង ៗ ជាឧទាហរណ៍ ។

## IV. លំនាំ

### ក សេចក្តីផ្តើម : វិធីដែលកុមាររៀនភាសា

- សួរសំណួរដូចខាងក្រោម :
  តើមនុស្សមានវិធីរៀនដូចគ្នាដែរឬទេ ?
- វិធីរៀនរបស់មនុស្សមិនដូចគ្នានោះទេ ។ ការយល់ដឹងរបស់មនុស្សលើជីវិតរស់នៅអាចមានលក្ខណៈខុស១គ្នាច្រើន

### ខ. ការលើកស្ទួយ " ការនិយាយ " ក្នុងថ្នាក់រៀន

- មានយុទ្ធវិធីជាច្រើនដែលគ្រូអាចប្រើប្រាស់បានដើម្បីធានាថាកុមារទាំងអស់មានឱកាសនិយាយក្នុងថ្នាក់រៀន ។ អ្នកសម្របសម្រួលសរសេរយុទ្ធវិធីនេះនៅលើក្តារខៀន ហើយផ្តល់ឧទាហរណ៍ជាក់ស្តែង ។

1. <u>ល្បែង :</u> ល្បែងសិក្សាមានប្រយោជន៍ជាច្រើន ហើយអាចធ្វើបានដោយប្រើសម្ភារដែលមិនពិបាករកដូចជា ក្រដាសកាតុង ពណ៌ទ្បេន ស្កុត ។ ល ។ កាលណាគ្រូបានរៀបចំល្បែងសិក្សាល្អ ៗ វាអាចជួយកុមាររៀនអំពី ពណ៌ រូបរាង លេខ ថ្ងៃ សត្វ និង បញ្ញត្តិផ្សេងទៀត ។

ឧទាហរណ៍ : ប៊ីងហ្គោ ជាល្បែងដែលកុមារអាចលេងជាក្រុមដោយខ្លួនឯងដែលមានកុមារម្នាក់ហៅលេខ ហើយកុមារដទៃទៀតធ្វើតាម ។ ល្បែងដទៃទៀតអាចជំរុញអោយកុមារបង្កើតសំណួរសួរទៅសិស្សដទៃទៀត ។ នេះជាបំណិនចាំបាច់ក្នុងការនិយាយ ។ អ្នកសម្របសម្រួលបង្ហាញ ឧទាហរណ៍ពីល្បែងផ្សេង ៗ ទៀតដូចជា :

- ល្បែងផ្គូផ្គងស្ដីពី ឈ្មោះថ្ងៃប្រចាំសប្ដាហ៍ និង ពណ៌ប្រចាំថ្ងៃ
- ល្បែងផ្គូផ្គងពីពាក្យទៅរូបភាព
- ល្បែងបង្វិលទ្រនិចផ្សេង ៗ អំពីការបូក ដក គុណ ចែកលេខ
- ល្បែង " យក្សថា "
- ល្បែង ២០ សំណួរ គឺជាល្បែងមួយដែលមាន ២ ក្រុម ។ ក្រុមទាំងពីរកាន់រូបភាពដូចគ្នា លើកលែងតែចំណុចមួយ ។ ក្រុមទី ១ សួរទៅក្រុមទី ២ ដើម្បីរកចំណុចខុសគ្នានោះដោយសួរមិនអោយលើសពី ២០ សំណួរឡើយ ។

<u>**ការណែនាំ**</u> **:** គ្រូអោយសិស្សធ្វើសកម្មភាពមានរបៀប ២ យ៉ាង :

- បើគ្រូថា " យក្សថា " សិស្សត្រូវតែធ្វើតាម
- បើគ្រូមិនប្រើពាក្យ " យក្សថា " ទេ សិស្សមិនត្រូវធ្វើតាមទេ អ្នកធ្វើខុស គឺគេមិនអនុញ្ញាតអោយលេងបន្តទេ ។

2. <u>**បទពិសោធន៍ក្នុងថ្នាក់រៀន**</u> **:** គ្រូអាចរៀបចំកិច្ចការងាយស្រួលក្នុងថ្នាក់រៀនដើម្បីអោយកុមារមានឱកាសបង្ហាញគំនិតដោយប្រើភាសានិយាយរបស់គេ ។ ជួនកាលសកម្មភាពនេះអាចតម្រូវអោយសិស្សពង្រីកលំនាំការគិតអំពីអ្វីដែលគេបានឃើញនៅក្នុងរូបភាព ឬ ដ្យាក្រាមណាមួយ ។ ឧទាហរណ៍ : កុមារអាចគូរផែនទីជនបទមួយនៅលើផ្ទាំងក្រដាសធំ ដោយគូរផ្ទះ ផ្លូវដើរ វាលស្រែ បឹង វត្ត . . . ។ ល ។ ក្រោយពីក្រុមនីមួយ ៗ បានគូររូបនោះរួចមក គ្រូអោយសិស្សពិពណ៌នាពីអ្វីខ្លះដែលក្រុមគេបានគូរព្រមទាំង និទានរឿងដោយប្រើរូបារម្មណ៍ស្ដីអំពីមូលដ្ឋានរបស់គេ ។ អោយសិស្សគិតដោយស្រមៃ

( តើមានអ្វីខ្លះនៅមុនពេលគេកសាងវត្ត ? ) តើប្អូន ៧ មានគំនិតយោបល់យ៉ាងដូចម្តេចដើម្បីកសាងភូមិរបស់ប្អូនក្នុងពេល ១០ ឆ្នាំទៅមុខទៀត ? សំណួរបែបនេះអាចជួយដល់ កុមារអោយចេះគិតដោយស្រមៃ និង និយាយអំពីអ្វីដែលហួសពីការពិពណ៌នារូបីរហូតដល់ការបង្ហាញគំនិតអរូបីក្នុងអនាគត ឬ អតីតកាល ។ អ្នកសម្របសម្រួល អាចព្យាយាមធ្វើសកម្មភាពនេះជាក់ស្តែងដោយយកសិក្ខាកាមជាសិស្ស ។

3. <u>សកម្មភាពទាក់ទងនឹងឥន្ទ្រិយារម្មណ៍</u> : សកម្មភាពនេះអាចផ្តល់ឱកាសច្រើនអោយសិស្សនិយាយ ។ ការសម្តែងឯតួ គឺ ជាឧទាហរណ៍ដ៏ល្អមួយចំពោះសកម្មភាពបែបនេះ ។ ការរៀបចំគំនិត និង រូបភាពតាមលំដាប់លំដោយ គឺជា ឧទាហរណ៍ល្អមួយទៀត ។ អ្នកសម្របសម្រួល ផ្តល់ឧទាហរណ៍ជាក់ស្តែងដល់សិក្ខាកាម :

- ការធ្វើតាមសេចក្តីណែនាំដោយចាប់ផ្តើមជាមួយសេចក្តីណែនាំខ្លី ៗ ហើយប្រែ ប្រួលសេចក្តីណែនាំទៅជាវែង និង លំបាកជាងមុន ។
- អោយកុមារជ្រើសរើសសន្លឹកបៀទៅតាមបញ្ជា ដូចជា : រើសសន្លឹកបៀ ២ ដែលមានពណ៌ខ្មៅ គឺ ជួង

<u>**និង ភេច និង រូបកញ្ញាស់ជួង ១ ។ ជ្រើសរើសសន្លឹក ការ៉ូ និង កឺ ពណ៌ក្រហមដែលមានលេខគូ . . . ។**</u>

- រៀបរូបភាពក្នុងរឿងតាមលំដាប់លំដោយ ។ ការរៀបចំលំដាប់លំដោយមួយប្រភេទទៀតតម្រូវអោយកុមាររៀបចំគំនិតរបស់ខ្លួនទៅតាមលំដាប់លំដោយនោះ ។ ការធ្វើបែបនេះអាចលំបាកជាងការរៀបចំលំដាប់លំដោយរូបភាព ។ សកម្មភាពមួយ ដែលមានប្រយោជន៍ជួយដល់កុមារក្នុងការបង្ហាញគំនិតរបស់ខ្លួនតាមលំដាប់លំដោយគឺជាការប្រើប្រាស់ពាក្យ " ក៏ប៉ុន្តែ ពេលនោះ បន្ទាប់មក ទោះជាយ៉ាងណាក៏ដោយ ម្យ៉ាងទៀត មួយវិញទៀត . . . " គ្រូអាចអោយកុមារនិទានរឿងដោយចាប់ផ្តើមពីល្បះដែលកំណត់ដោយគ្រូ បន្ទាប់មកសិស្សបន្តនិទានរឿងដោយប្រើពាក្យ " ភ្ជាប់ " ។ សិស្សត្រូវបំពេញល្បះថ្មីដែលភ្ជាប់នឹងល្បះពីមុន ។ ឧទាហរណ៍ : " ថ្ងៃមួយខ្ញុំទៅវាលស្រែក៏ប៉ុន្តែមេឃបានភ្លៀងយ៉ាងខ្លាំងហើយខ្ញុំបានជ្រកភ្លៀងក្រោមដើមឈើ " ។ សិស្សម្នាក់ផ្សេងទៀតត្រូវនិយាយល្បះដូចគ្នា ឬ អាចនិយាយល្បះបន្តផ្សេងទៀត ដូចជា " ថ្ងៃមួយខ្ញុំបានទៅវាលស្រែ ។ ក៏ប៉ុន្តែ . . . " ។

# ផែបបទទី ៤ : ការបង្រៀនភាសា : សារសំខាន់នៃអំណាន

**គោលបំណង**

- សិក្ខាកាម ពិពណ៌នាអំពីកត្តាដែលប៉ះពាល់ដល់ការរៀនអំណានរបស់កុមារ
- សិក្ខាកាម ចេះប្រើយុទ្ធវិធីផ្សេង ៗ ដើម្បីជួយកុមារដែលមានការលំបាកក្នុងការអាន ។

**រយៈពេល**

៣ ទៅ ៤ ម៉ោង

**សម្ភារ**

- ក្រដាសផ្ទាំងធំ
- ហ្វឺត
- ស្កុត
- ល្បែងផ្សេង ៗ ។

## លំនាំបង្រៀន

ក. សេចក្តីផ្តើម : មូលហេតុដែលកុមារមួយចំនួនពិបាករៀនអំណាន ?

- អ្នកសម្របសម្រួល ចាប់ពន្យល់ពីយុទ្ធវិធីបង្រៀនអំណាន ។ ធ្វើបញ្ជីអំពីយុទ្ធវិធីខ្លះ ៗ ជាមួយសិក្ខាកាមជាក្រុមធំ ។ <u>ឧទាហរណ៍</u> :
  - បកស្រាយសូរសម្លេងអក្សរ
  - ការបង្រៀននៃពាក្យសំខាន់ ៗ ដែលប្រើញឹកញាប់
  - ការបង្រៀនអំណាន ដោយអោយសិស្សអាន
  - ការបង្រៀនដោយផ្គូផ្គងពីពាក្យទៅរូប
  - ការបកស្រាយនិយមន័យរបស់ពាក្យ ដោយប្រើពាក្យគន្លឹះ ( ការវិភាគអត្ថន័យ ) ។ល ។
- គ្មាននរណាដឹងច្បាស់អំពីរបៀបដែលកុមាររៀនអាន ។ វិធីចេះអានមានលក្ខណៈខុស ៗ គ្នាទៅតាមបុគ្គល ។ ពេលណាយើងរំលឹកពីបទពិសោធផ្ទាល់នៃការរៀនអាន យើងពិបាកកំណត់វិធីណាខ្លះដែល

បង្កអោយយើងចេះអាន ។ ដូចនេះមានអាចិកំបាំងមួយចំនួនដែលទាក់ទងទៅដល់លំនាំការចេះអាន ។ កុមារដែលកំពុងតែរៀនអានជំហានដំបូងមានការភ័យខ្លាច ។ កុមារដែលមានការលំបាកក្នុងការរៀនសូត្រអាចមានភាពអស់ទឹកចិត្ត ពេលសង្កេតឃើញថា មិត្តរបស់វាអាចអានបាន ។ ដូចនេះកុមារដែលរៀនមិនទាន់គេអាចនាំអោយគេគិតតែភាពបរាជ័យ ។ ការគិតលើភាពបរាជ័យជានិច្ចអាចនាំអោយភាពបរាជ័យកើតឡើងទៀតនៅពេលអនាគត ។ ពេលដែលកុមារទទួលការបរាជ័យក្នុងការរៀនអាន គេមាន ភាពអៀន ដែលនាំអោយគេបាក់ទឹកចិត្តក្នុងការចង់រៀនអានទៀតផង ។

- គ្រូមួយចំនួនយល់ច្រឡំថា ការអានលឺរបស់សិស្ស ក៏ដូចជាការអានយល់ផងដែរ ។ គ្រូមិនដែលគិតថា កុមារត្រូវយល់នូវអ្វីដែលគេបានអានមិនមែនជាការបកស្រាយសូរសម្លេងអក្សរ និង ពាក្យតែប៉ុណ្ណោះទេ ។ ពេលណាគ្រូបង្រៀនអំណានបែបនេះគេបានផ្តាច់អំណានពីបរិបទដែលមានន័យ ។ ដើម្បីបញ្ជាក់គំនិតនេះអោយកាន់តែច្បាស់ អ្នកសម្របសម្រួលសរសេរល្បះមួយជាភាសាបរទេសដែល សិក្ខាកាមមិនចេះ (ដូចជាភាសាថៃ) នៅលើក្តាខៀន ÷

| |
|---|
| ยามมียา ( យ៉ាម មី យ៉ា ) |

- 
- អានល្បះនេះអោយសិក្ខាកាមស្តាប់ ហើយអោយគេអានតាម ។ ក្រោយពីសិក្ខាកាមវែកញែកពាក្យបរទេសនីមួយ ៗ នេះបាន សួរសិក្ខាកាមតើគេចេះអានពាក្យថៃ នេះ ដែរឬទេ ? ។ ទោះបីមានគ្រូមួយចំនួនឆ្លើយថា " អានបាន " អ្នកសម្របសម្រួល គួរបញ្ជាក់ គេគ្រាន់តែចេះបកស្រាយសូរពាក្យតែប៉ុណ្ណោះ គេមិនទាន់យល់ន័យរបស់ពាក្យដែលគេបានអាននោះទេ ។ កើតឡើងជាញឹកញាប់នៅក្នុងថ្នាក់រៀនពេលគ្រូបង្រៀនអំណាន ។ កុមារអានលឺពាក្យ និង ល្បះមួយចំនួនក៏ប៉ុន្តែគេមិនទាន់យល់ន័យរបស់ពាក្យអ្វីដែលគេបានអាន ។ លំនាំនៃការអានមានលក្ខណៈបែបនេះ គឺជាការអានគ្មានន័យ ។
- អ្នកសម្របសម្រួល សង្ខេបចំណុចសំខាន់ ៗ ស្តីពីអ្វីដែលគ្រូត្រូវចាំនៅពេលបង្រៀនអំណានដូចខាងក្រោម ÷
  - ការពារមិនអោយកុមារអស់ទឹកចិត្ត ពេលណាគេរៀនអានមិនទាន់មិត្តភក្តិ
  - រៀបចំនូវបរិបទមានន័យពេលណាបង្រៀនអំណាន (ឧទាហរណ៍ : ការអានកាសែត អានផ្លាកកំប៉ុង ការអានផ្លាកសញ្ញា ។ល ។

- ប្រើយុទ្ធវិធីច្រើនយ៉ាងពេលបង្រៀន ( អនុមាណរួម . អនុមាណញែក . ការប្រើពាក្យគន្លឹះ ត្រូវចងចាំថា ការអានអោយឮមិនមែនមានន័យថាសិស្សយល់ន័យរបស់ពាក្យនោះទេ ។

**ខ. ការរៀបចំកម្មវិធីបំប៉នបន្ថែមស្តីពីអំណាន[1]**

- អ្នកសម្របសម្រួល គួរតែព្យាយាមបង្ហាញនូវវិធីនីមួយៗ នេះដោយប្រើប្រាស់សិក្ខាកាមជាសិស្ស ÷

1. <u>អំណានដោយគ្មានស្រៈ</u> :

- ក្នុងវិធីនេះ កុមារធ្វើការងារជាដៃគូ ។ សមាជិកក្នុងគូនីមួយ ៗ ត្រូវ បានទទួលនូវអត្ថបទខុស ៗ គ្នា ( ពីរ ឬ បីល្បះ ) កុមារម្នាក់ៗ សរសេរអត្ថបទឡើងវិញដោយលុបចោលស្រៈទាំងអស់ ។ ឧទាហរណ៍ : អត្ថបទដែលគ្មានស្រៈ ( លើកលែងពាក្យ " បាន " និង ស្រៈពេញតួ ) ។

| |
|---|
| ន ខ កត្តក ឆ្ន មន ខ្ញ បាន ទ លង ផ្ទ ឪពុក ម ខ្ញ ន ស្រក ស្រ ។ ព្រក ព្រលម មយ ច អ័ព្ទ យ៉ ង ខ្ល ង ។ |

- ក្រោយមកកុមារក្នុងគូនីមួយ ៗ ដូរអត្ថបទគ្នាទៅវិញទៅមកហើយព្យាយាម អានស្ងាត់ជាបុគ្គល ។ អ្នកអានត្រូវបកស្រាយ តើពាក្យគ្មានស្រៈ នោះ ជាអ្វី ។ លំហាត់លុបស្រះនេះមានលទ្ធផលវិជ្ជមានចំពោះកុមារ ។ លទ្ធផលសំខាន់បំផុត គឺអ្នកអានមើលពាក្យទៅខាងមុខដើម្បីរកពាក្យគន្លឹះដែលអាចជួយបកស្រាយពាក្យដែលខ្វះស្រៈ ។ ការប្រើពាក្យគន្លឹះនៃអំណានជាវិធីដែលអ្នកអានទាំងអស់ប្រើប្រាស់ដើម្បីអានអត្ថបទណាមួយ ។ ក៏ប៉ុន្តែគ្រូភាគច្រើនមិនដែលប្រើវិធីនេះ ។ ផលប្រយោជន៍មួយទៀតរបស់លំហាត់នេះ គឺអ្នកអានយល់កាន់តែច្បាស់ពីមុខងាររបស់ស្រៈក្នុងភាសា ។ មានន័យថាយើងពិបាកអានពាក្យអោយឮដោយបន្លឺសូររវាងព្យញ្ជនៈទៅនឹងស្រៈ ប្រសិនបើគ្មានស្រៈ ។
- លំហាត់បែបនេះជួយបញ្ជាក់លក្ខណៈជាក់ស្តែងរបស់ពាក្យ ( មុខងារពិតរបស់ស្រៈ និង ព្យញ្ជនៈក្នុងភាសា ) ។ ក៏ប៉ុន្តែពាក្យដែលបង្រៀននោះមិនបានផ្តាច់ពីន័យ ហើយបរិបទជុំវិញជួយអោយយើងយល់ន័យរបស់វា ។

**2.** ការប្តូរព្យញ្ជនៈ :

- ដោយរៀបចំកុមារជាដៃគូ ដូចខាងលើ អោយកុមារសរសេរអត្ថបទខ្លីឡើងវិញ ដោយប្តូរព្យញ្ជនៈពីរដែលបានជ្រើសរើសដោយសិស្ស ។

  ឧទាហរណ៍ :

| |
|---|
| នៅ កែ ខក្តិក ឆ្នាំ មុន ក្ុំ បាន ទៅ លេង ផ្ទះ ឪពុក មា ក្ុំ នៅ ស្រុខ ស្រែ ព្រឹខ ព្រលឹម មេឃ ចុះអ័ព្ទ យ៉ាង ក្លាំង ។ |

- ក្នុងឧទាហរណ៍ខាងលើ ព្យញ្ជនៈ " ខ " ចំនួន ៣ បានកែទៅជាព្យញ្ជនៈ " ក " និង ព្យញ្ជនៈ " ក " ចំនួន ៣ បានកែទៅជាព្យញ្ជនៈ " ខ "អោយកុមារបកស្រាយអត្ថបទនោះដូចលំហាត់លុបស្រះខាងលើ ។ លំហាត់បែបនេះសមស្របសម្រាប់សិស្សបឋមសិក្សាកម្រិតខ្ពស់ ថ្នាក់ទី ៤ - ៥ និង ថ្នាក់ទី ៦ ។

**3.** ល្បែងពាក្យ :

- សកម្មភាពលេងជាមួយពាក្យ និង តួអក្សរអាចជួយកុមារភ្ជាប់ពាក្យជាមួយន័យរបស់វា ។ មានពាក្យជាច្រើនដែលអាចផ្លាស់ប្តូរទៅជារូបភាព ដើម្បីបង្ហាញន័យរបស់វា ។ មើលឧទាហរណ៍ដូចខាងក្រោម ÷



- ល្បែងបែបនេះ អាចជួយកុមារមានបំរុងប្រយ័ត្នក្នុងការសង្កេតពាក្យនិងវិធីសរសេរពាក្យ ។

### ៤. ការប្រើប័ណ្ណ ៖

- ការប្រើប័ណ្ណពាក្យ ប័ណ្ណព្យញ្ជនៈ និង ប័ណ្ណស្រៈ ជាវិធីមួយដែលអាចជួយដល់សិស្សក្នុងការបង្កើតពាក្យ និង ល្បះដោយមិនចាំបាច់សរសេរ ។ គ្រូ ចែកប័ណ្ណរូបភាព និង ប័ណ្ណព្យញ្ជនៈមួយចំនួនតាមក្រុមសិស្ស ។ យក ដីស គូសប្រអប់កណ្តាល តុ ក្នុងក្រុម ហើយពន្យល់សិស្សធ្វើគ្រប់សកម្មភាពទាំងអស់ក្នុងប្រអប់នោះ ។ ការធ្វើបែបនេះជួយបំរុងប្រយ័ត្នស្មារតីរបស់កុមារតូច ៗ ។ កុមារយកប័ណ្ណរបស់គេរៀបជុំវិញប្រអប់ដែលបានគូរ ។
- ចាប់ផ្តើមមេរៀនដោយបង្ហាញរូបភាពទៅសិស្ស ហើយសួរកុមារថា " តើរូបភាពនេះបង្ហាញ អំពីអ្វី ? " អោយកុមារដែលកំពុងកាន់រូបភាពនោះដាក់វាទៅក្នុងប្រអប់ ។ ក្រោយមកសួរសិស្សថា " តើរូបភាពនោះផ្តើមដោយសូរអ្វី ? " គ្រូសរសេរតួអក្សរនោះនៅលើក្តារខៀនទៅតាមចម្លើយរបស់សិស្ស ។ អោយកុមារដែលកាន់ប័ណ្ណព្យញ្ជនៈនេះដាក់ក្នុងប្រអប់កណ្តាលតុ ។ វិធីនេះអាចប្រើបាន ដើម្បីបង្កើតពាក្យ ឃ្លា ឬ ល្បះ ។

# បែបបទទី ៥ : ការបង្រៀនគណិតវិទ្យា

## គោលបំណង

- សិក្ខាកាម ពិពណ៌នាឧបសគ្គក្នុងការយល់បញ្ញត្តិគណិតវិទ្យា
- សិក្ខាកាម ចេះប្រើយុទ្ធវិធីដើម្បីជួយពង្រឹងការរៀនសូត្ររបស់កុមារ ។

## រយៈពេល

៣ ទៅ ៤ ម៉ោង

## សម្ភារ

- ក្រដាសផ្ទាំងធំ
- ហ្វឺត
- ស្កុត
- សម្ភារចំពោះសកម្មភាពផ្សេង ៗ ។

## លំនាំបង្រៀន

ក. សេចក្តីផ្តើម : ហេតុអ្វីបានជាកុមារមួយចំនួនជួបការលំបាកក្នុងការសិក្សាគណិតវិទ្យា ?

- ត្រួតពិនិត្យឡើងវិញរាល់ឧបសគ្គ ដែលកុមារធ្លាប់ជួបប្រទះកន្លងមក ក្នុងការរៀនប្រមាណវិធីបូក ដក គុណ និង ចែក ។ អ្នកសម្របសម្រួល ពន្យល់ឧបសគ្គខាងក្រោមនេះ ÷
    - សិស្សមិនយល់ និង មិនចងចាំលើតារាងមេលេខ ( 1 + 1 = 2 , 1 + 2 = 3 ។ ល ។ )
    - សិស្សពិបាកយល់ពាក្យបច្ចេកទេសគណិតវិទ្យា
    - សិស្សមិនចាំលំដាប់លំដោយជំហានផ្សេង ៗ ដែលត្រូវអនុវត្តន៍ក្នុងការដោះស្រាយចំណោទ

      សិស្សពិបាករកទំនាក់ទំនងរវាងបញ្ញត្តិ ឬ វិធានគណិតវិទ្យា

      ឧទាហរណ៍ : - ការគុណ គឺជាការបូកលេខបន្ត

      - វិធីផ្គុំ ( ត្រាទុក )

- ក្រោយពីបានពិភាក្សាអំពីបញ្ហាខាងលើនេះ អ្នកសម្របសម្រួលបង្ហាញអំពីមូលហេតុមួយចំនួនដែល ដែលនាំអោយកុមារពិបាកយល់បញ្ញត្តិ ឬ វិធានគណិតវិទ្យា ។ អ្នកសម្របសម្រួលបិទក្រដាសផ្ទាំង ធំលើក្តារខៀន និង ពិភាក្សាជាមួយសិក្ខាកាម ÷

<u>តារាង ក</u> : <u>បញ្ហាការបង្រៀនគណិតវិទ្យា</u>

*កុមារពិបាកយល់បញ្ញត្តិគណិតវិទ្យាពីព្រោះ ÷*

១. គ្រូប្រើវិធីដែលគ្មានន័យសម្រាប់កុមារ ( ឧ. ការសូត្រមេលេខ ការចងចាំនូវប្រមាណវិធីផ្សេង ៗ ដោយ គ្មានការអនុវត្តជាក់ស្តែង )

២. គ្រូបង្រៀនបញ្ញត្តិដែលគ្មានទំនាក់ទំនងជាមួយបទពិសោធន៍របស់កុមារ ( ឧ. គ្រូបង្រៀន បញ្ញត្តិ " លេខ " ទៅជាការបង្រៀនរបៀបអរូបីដោយមិនបានប្រើវត្ថុរូបីជាមុន )

<u>៣. គ្រូពន្យល់បញ្ញត្តិពិបាកដោយប្រើពាក្យបច្ចេកទេស ដែលសិស្សមិនយល់ ( ឧ. ខ្ទង់ . មេគុណ . លទ្ធផល . សង្ទីម៉ែត្រ )</u>

៤. គ្រូពន្យល់បញ្ញត្តិក្នុងបរិបទគ្មានន័យ (ឧ. គ្រូអោយសិស្សធ្វើលំហាត់ដែលគ្មានទំនាក់ទំនងជាមួយ ជីវិតរស់នៅ <u>ជាក់ស្តែងរបស់កុមារ ) ។</u>

- អ្នកសម្របសម្រួលណែនាំការពិភាក្សាអោយសិក្ខាកាមពិចារណាលើទម្លាប់បង្រៀនរបស់គេម្នាក់ៗ។ តើគ្រូអាចទទួលស្គាល់ថា មានបញ្ហាដូចខាងលើពិតមែនឬទេ ? អោយសិក្ខាកាមទទួលស្គាល់ថា គ្រូមួយចំនួនគិតតែចាប់កំហុសរបស់សិស្សតែមិនគិតពីកំហុសនៃការបង្រៀនរបស់គាត់ ។
- សិក្ខាកាមបំពេញបញ្ជីសំណួរដែលបង្ហាញក្នុងប្រអប់ខាងក្រោមនេះ ។ អ្នកសម្របសម្រួល អាចប្រែប្រួលបញ្ជីសំណួរនេះទៅតាមបទពិសោធន៍នៅមូលដ្ឋាន ដោយរកឧទាហរណ៍ជាក់ស្តែងនៃការបង្រៀនក្នុងមូលដ្ឋាននោះ ។

| តារាង ខ :បញ្ជីសំណួរវាយតម្លៃផ្ទាល់ខ្លួន ស្តីពីវិធីបង្រៀនគណិតវិទ្យា ( ជាឧទាហរណ៍ )<br>ការណែនាំ : ចូរឆ្លើយសំណួរខាងក្រោមដោយសរសេរ " បាទ" ឬ " ទេ" ក្នុងបន្ទាត់<br>នីមួយ ៗ | | |
|---|---|---|
| ១. តើអ្នកអោយកុមារសូត្រមេលេខជាញឹកញាប់ក្នុងថ្នាក់ដែរឬទេ ?<br>២. តើអ្នកគិតថា កុមារភាគច្រើនធ្លាប់ឃើញសញ្ញាបូក និង សញ្ញាដកមុនពេលដែលគេចូលរៀនដែរឬទេ ?<br>៣. តើអ្នកអនុញ្ញាតអោយកុមារដោះស្រាយចំណោទដោយប្រើល្បិចផ្ទាល់ខ្លួនរបស់គេជំនួសល្បិចដែលបានបង្រៀនក្នុងថ្នាក់ដែរឬទេ ?<br>៤. តើសិស្សរបស់អ្នកប្រើប្រាស់ពេលវេលាភាគច្រើននៅលើការដោះស្រាយចំណោទជាលេខជំនួសចំណោទជាភាសាសរសេរដែរឬទេ ?<br>៥. ពេលណាសិស្សមិនយល់បញ្ញត្តិគណិតវិទ្យាណាមួយតើអ្នកបង្រៀនបញ្ញត្តិនេះឡើងវិញដោយប្រើរបៀបដដែល ៗ ឬទេ ? | បាទ | ទេ |

- ក្រោយពីសិក្ខាកាមបានឆ្លើយសំណួរនីមួយ ៗ រួច អ្នកសម្របសម្រួលបូកសរុបចម្លើយផ្សេង ៗ ។ អ្នកសម្របសម្រួល អោយសិក្ខាកាមប្រៀបធៀបចម្លើយពីតារាង ខ ទៅនឹងតារាង ក ដោយកំណត់បញ្ហាដែលមានក្នុងតារាង ក ។

## ខ. ការអភិវឌ្ឍការយល់ដឹងបញ្ញត្តិគណិតវិទ្យា :

- ចំណុចសំខាន់មួយដែលត្រូវបញ្ជាក់ គឺថា គ្រូមួយចំនួនបង្រៀនគណិតវិទ្យាតែអោយលក្ខណៈចងចាំ
- ក្បួនច្បាប់ និង រូបមន្ត ។ វិធីសាស្ត្របង្រៀនបែបនេះប្រាកដជាមិននាំអោយកុមារយល់បានពី
- បញ្ញត្តិគណិតវិទ្យាឡើយ ។
- អ្នកសម្របសម្រួលសួរសិក្ខាកាម តើយើងអាចដឹងថា សិស្សយល់ដឹងពីខ្លឹមសារគណិតវិទ្យាយ៉ាងដូចម្តេច ?
- គ្រូមួយចំនួនអាចឆ្លើយថា ការដោះស្រាយចំណោទជាលេខគឺជាសញ្ញាល្អស្តីពីការយល់ដឹងគណិតវិទ្យារបស់កុមារ ។ ទោះជាយ៉ាងណាក៏ដោយមានសញ្ញាមួយទៀតដែលល្អជាងសម្រាប់បង្ហាញការយល់ដឹងគណិតវិទ្យារបស់កុមារ ។ សញ្ញានេះ គឺជាសមត្ថភាពរបស់សិស្សក្នុងការផ្លាស់ប្តូរពត៌មានពីទម្រង់មួយទៅជាទម្រង់មួយផ្សេងទៀត ។ ក្នុងគណិតវិទ្យាមានសកម្មភាព ៤ ប្រភេទ ÷

១. សិស្សប្រើវត្ថុរូបី ( ឧ. ការរាប់បំពង់បឺត . . . )

២. សិស្សប្រើសញ្ញា ( ឧ. លេខ . . . )

៣. សិស្សប្រើប្រាស់ភាសា ( ឧ. ចំណោទជាភាសា . . . )

៤. សិស្សប្រើប្រាស់រូបភាព ( ឧ. លេខបន្ទាត់ក្រឹត. ក្រាហ្វិក . . . )

- ពេលណាកុមារប្រែប្រួលចំណេះដឹងពីទម្រង់មួយទៅទម្រង់មួយផ្សេងទៀត នេះមានន័យថា សិស្ស " យល់ " ។ នៅក្នុងសកម្មភាពក្រុមតូច អ្នកសម្របសម្រួលអោយសិក្ខាកាមបង្កើតសំណួរចំនួន ពីរ ដែលបង្ហាញការប្រែប្រួលចំណេះដឹងពីទម្រង់មួយទៅទម្រង់មួយផ្សេងទៀត ។ ក្រុមនីមួយ ៗ បញ្ជាក់ពីប្រភេទនៃការប្រែប្រួល ។

<u>ឧទាហរណ៍</u> :

| |
|---|
| ចាន់ថន មានមាន់ចំនួន ៥ ក្បាល ។ ក៏ប៉ុន្តែមាន់បានងាប់ចំនួន ១ ក្បាល ។ តើចាន់ថន<br>នៅសល់មាន់ចំនួនប៉ុន្មានក្បាល ? ចូរបង្ហាញចំណោទនេះដោយប្រើ លេខ ។<br>5 – 1 = 4<br>⟶ |

- គ្រូត្រូវតែកាត់បន្ថយការបង្រៀនស្តីអំពីក្បួនច្បាប់ បែបទន្ទេញចាំមាត់ សម្រាប់យកមកដោះស្រាយបញ្ហាចំណោទ ពីព្រោះការធ្វើបែបនេះមិននាំអោយសិស្សស៊ីជំរៅពីបញ្ញត្តិទេ ។ បង្ហាញសកម្មភាពខាងក្រោមនេះ ដើម្បីបញ្ជាក់ទៅលើលំនាំក្នុងការយល់បញ្ញត្តិ ÷

| |
|---|
| <u>សកម្មភាពទី ១</u> : **លំដាប់លំដោយនៃការប្រែប្រួលចំណេះដឹង** |
| ក្នុងសកម្មភាពនេះសិស្សត្រូវប្រែប្រួលចំណេះដឹងទៅតាមលំដាប់លំដោយដែលបានកំណត់ ÷ |
| <u>ឧទាហរណ៍</u> : ចំណោទ ភាសា ⟶ សរសេរជាសញ្ញា ⟶ បង្ហាញដោយប្រើវត្ថុរូបី ⟶ បង្ហាញតាមបន្ទាត់ក្រឹត |
| លំដាប់លំដោយនៃការប្រែប្រួលត្រូវបានកំណត់ដោយគ្រូ ។ រួចសិស្សត្រូវតែអនុវត្តទៅតាម |
| ***ឧទាហរណ៍ :*** ចំណោទជាភាសា : ចាន់ថនមានប៊ិច ២៨ ដើម ។ ភាពមានប៊ិច ១៣ ដើម ។ តើភាពមានប៊ិចតិចជាងចាន់ថនប៉ុន្មានដើម ? |
| **<u>ជាដំបូងក្រុមសិស្សត្រូវសរសេរចំណោទភាសានេះជាសញ្ញា " ២៨ - ១៣ " រួចរៀបចំបំពង់បឹតស្តីពីប្រមាណវិធី</u>** |
| ដកនេះ បន្ទាប់បង្ហាញតាមលេខបន្ទាត់ក្រឹត ។ ក្រោយពីក្រុមសិស្សបានបង្ហាញពីភាពប្រែប្រួលទាំងឡាយនោះ គេត្រូវបង្ហាញលទ្ធផលដល់គ្រូ ។ ក្នុងកិច្ចការថ្មី គ្រូអាចផ្លាស់ប្តូរលំដាប់លំដោយនៃការប្រែប្រួលចំណេះដឹងទៅប្រភេទមួយផ្សេងទៀត ។ |

គ. បញ្ហាភាសាក្នុងគណិតវិទ្យា :

- សិស្សជួបបញ្ហាជាញឹកញាប់ក្នុងគណិតវិទ្យា ដោយសារការប្រើប្រាស់ភាសា ។ គ្រូមួយចំនួនគិតថាកុមារងាយស្រួលយល់ការផ្លាស់ប្តូរទម្រង់ពីពាក្យទៅលេខ ពីលេខទៅពាក្យ ។ នេះជាការយល់ច្រឡំរបស់គ្រូ ។ គ្រូត្រូវតែរៀបចំសកម្មភាពពិសេសដែលអាចជួយកុមារពង្រឹងសមត្ថភាពផ្លាស់ប្តូរទម្រង់ពីភាសាទៅសញ្ញា ឬ ពីសញ្ញាទៅភាសា ។

<u>ឧទាហរណ៍</u> : ពាក្យមួយចំនួនអាចបង្ហាញពីប្រមាណវិធីផ្សេង ៗ ដូចតទៅ ÷

- នៃ : ការគុណ ( ប្រភាគ )
- ច្រើនជាង : ការបូក

<u>ឧទាហរណ៍</u> : ១. សុខ មានឃ្លី ១៥ គ្រាប់ ។ សៅ មានឃ្លីច្រើនជាងសុខ ៣ គ្រាប់ ។ តើសៅមានឃ្លីប៉ុន្មានគ្រាប់ ? ( បូក )

២. សុខ មានឃ្លី ១៥ គ្រាប់ ។ សៅ មានឃ្លីច្រើនជាងសុខ ២ ដង ។ តើសៅមានឃ្លីប៉ុន្មានគ្រាប់ ? ( គុណ ឬ បូក )

- តិចជាង : ការដក

<u>ឧទាហរណ៍</u> : ១. សុខា មានប្រាក់ ១០០០ ៛ ។ សុភីមានប្រាក់តិចជាងសុខា ២០០ ៛ ។ តើសុភីមានប៉ុន្មាន ? ( ដក )

២. សុខា មានមាន់ចំនួន ៨ ក្បាល តិចជាង តារា ចំនួន ២ ក្បាល ។ តើតារាមានមាន់ចំនួនប៉ុន្មានក្បាល ? ( បូក )

- ចែកជា : ការចែក
- ដង : ការគុណ
- ទាំងអស់គ្នា : ការបូក
- បែងចែក : ការចែក
- នីមួយៗ : ការចែក

<u>**បញ្ជាក់**</u> : គ្រប់ពាក្យទាំងអស់អាចប្រែប្រួលទៅតាមខ្លឹមសារនៃសំណួរ ។

- បង្ហាញសកម្មភាពដូចខាងក្រោមដល់សិក្ខាកាម ។ អ្នកសម្របសម្រួល ជួយសិក្ខាកាមបង្កើតសកម្មភាពផ្ទាល់ខ្លួនរបស់គេដោយយកមេរៀនជាក់ស្តែងពីកម្មវិធីសិក្សា ព្រមទាំងគំនិតដែលបានបង្ហាញក្នុងសកម្មភាពខាងក្រោម ÷

**<u>សកម្មភាពទី ២</u>  :** **ការបង្កើតល្បះក្នុងគណិតវិទ្យា**

ចែកប័ណ្ណពាក្យមួយចំនួនដែលមានពាក្យដូចជា " [៣] [៤] [៣ ដង] [៤ ដង] [១២] [ស្មើ] [ចែកនឹង] [គុណនឹង] " ។

ព្រមទាំងប័ណ្ណលេខចំនួន ៣ ដែលមានលេខដូចតទៅ (ឧ. ៣ ៤ និង ១២ ដល់សិស្សជាក្រុមតូច ។ ចែកបំពង់បឺតទៅតាមក្រុមនីមួយ ៗ ផងដែរ ។ ក្រុមនីមួយ ៗ ត្រូវបង្កើតល្បះគណិតវិទ្យាអោយបានច្រើនបំផុតដែលអាចធ្វើបាន ÷

- [៣] [៤ ដង] [ស្មើ] [១២]
- [៤] [៣ ដង] [ស្មើ] [១២]
- [១២] [ចែកនឹង] [៣] [ស្មើ] [៤]
- [១២] [ចែកនឹង] [៤] [ស្មើ] [៣]
- [៣] [គុណនឹង] [៤] [ស្មើ] [១២]

**<u>ក្រោយពីសិស្សបានរៀបចំល្បះគណិតវិទ្យាដោយប្រើប័ណ្ណដូចខាងលើ</u>**

**<u>គេត្រូវយកបំពង់បឺតដើម្បីបង្ហាញ ល្បះគណិតវិទ្យានេះ ។</u>**

<u>សកម្មភាពទី ៣ :</u> ច្រើនជាង និង តិចជាង

សកម្មភាពនេះអាចជួយកុមារចេះភ្ជាប់ពាក្យ " តិចជាង " និង " ច្រើនជាង " ទៅនឹងប្រមាណវិធីដក ។ សកម្មភាពនេះត្រូវប្រើម៉ាស៊ីនគិតលេខ ។ ជាដំបូងត្រូវគូសប្រអប់ចំនួន ៤ នៅលើតុ ហើយដាក់អក្សរ ក . ខ . គ . ឃ. ពីខាងក្រោម ។ យកប័ណ្ណ ២ សម្រាប់ ដែលមានលេខ ១ ដល់លេខ ១០០ ហើយដាក់១ សម្រាប់ក្នុងប្រអប់ " ក " និងមួយទៀតក្នុងប្រអប់ " គ "។ ដាក់ម៉ាស៊ីនគិតលេខក្នុងប្រអប់ " ឃ " ដាក់ប័ណ្ណមួយដែលមានពាក្យ " ច្រើនជាង " មួយខាង និង " តិចជាង " មួយខាងដាក់ក្នុងប្រអប់ " ខ " យកជីស សរសេរពាក្យ " គឺចំនួន " រវាងចន្លោះប្រអប់ " គ " និងប្រអប់ " ឃ " ។ សិស្សនីមួយៗ ក្នុងក្រុម បើក ប័ណ្ណលេខនៅក្នុងប្រអប់ " ក " និងប្រអប់ " គ " ។ សិស្សទាំងអស់ក្នុងក្រុម ត្រូវសម្រេចចិត្តថា តើលេខ ដែលបានបង្ហាញនូវក្នុងប្រអប់ " ក " មានចំនួនតិចជាង ឬ ច្រើនជាងក្នុងប្រអប់ " គ " រួចបង្ហាញពាក្យ " តិចជាង ឬ ច្រើនជាង " ក្នុងប្រអប់ " ខ " ។ បន្ទាប់មកសិស្សត្រូវគិតដោយប្រើម៉ាស៊ីនគិតលេខដើម្បីរកភាពខុសគ្នារវាងចំនួនទាំង២
ដាក់ម៉ាស៊ីនគិតលេខនៅក្នុងប្រអប់ " ឃ " ដើម្បី
បង្ហាញល្បះគណិតវិទ្យាដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ÷




ឃ. ការរៀនគណិតវិទ្យាដែលមានទំនាក់ទំនងទៅនឹងជីវិតជាក់ស្តែង :

- ពិភាក្សាជាមួយសិក្ខាកាមអំពីការរៀបចំសកម្មភាពដោះស្រាយចំណោទទាក់ទងនឹងជីវិតជាក់ស្តែង ។ ចំពោះសិស្សដែលមានសេចក្តីត្រូវការពិសេសក្នុងការរៀនសូត្រ កិច្ចការដែលគ្មានទំនាក់ទំនងជាមួយជីវភាពរស់នៅជាក់ស្តែង ( ឧ. ដោះស្រាយចំណោទលេខ ) គឺជាឧបសគ្គធំសម្រាប់កុមារនេះ ។ គ្រូគួរតែបង្កើតសកម្មភាពអំពីបញ្ញត្តិគណិតវិទ្យាដែលមានទំនាក់ទំនងទៅនឹងជីវិតរស់នៅជាក់ស្តែង របស់កុមារ ។ ការរៀបចំផ្សារប្រឌិត និង ការសម្តែងតួ គឺជាវិធីដ៏ល្អសម្រាប់ការសម្រេចនូវគោល បំណងនេះ ។ បង្ហាញសកម្មភាពខាងក្រោមជាសកម្មភាពជាក់ស្តែងមួយ ÷

**សកម្មភាពទី ៤ :** **ផ្សារប្រឌិត**

សកម្មភាពនេះពង្រឹងប្រមាណវិធីបូក និង ដក ដោយអោយសិស្សធ្វើសកម្មភាពរបៀបទីផ្សារ ។ បែងចែកសិស្សជា ២ ក្រុម : ក្រុមអ្នកលក់ និង ក្រុមអ្នកទិញ ។ អ្នកទិញត្រូវទទួលប្រាក់សិប្បនិម្មិត ចំនួន ១0000៛ ដែលមានប្រភេទប្រាក់ក្រដាស ១00៛ ២00៛ ៥00៛ និង ១000៛ ។ អ្នកលក់ត្រូវទទួលប័ណ្ណរូបបង្ហាញរបស់ផ្សេង ៗ ដូចជា ខោអាវ ម្ហូបអាហារ ( សាច់មាន់ . សាច់ជ្រូក . ផ្លែស្វាយ ។ ល ។ ) ។ ប័ណ្ណនីមួយ ៗ ត្រូវមានរូបភាពព្រមទាំងតម្លៃសរសេរខាងក្រោមប័ណ្ណនេះអ្នកទិញត្រូវទិញរបស់យ៉ាងតិច ៣ មុខ ។ អ្នកលក់ត្រូវលក់របស់ទាំងនោះដោយចេះអាប់ប្រាក់ ។ អ្នកទិញត្រូវត្រួតពិនិត្យ តើប្រាក់អាប់ត្រឹមត្រូវឬទេ ? ពេលណាសកម្មភាពនេះត្រូវបានបញ្ចប់ អោយអ្នកទិញត្រួតពិនិត្យអ្វីដែលគេបានទិញ ដោយបូកសរុប តម្លៃហើយប្រៀបធៀបតាមប្រាក់ដែលគេនៅសល់ ។ ចំនួនប្រាក់សរុបត្រូវស្មើនឹងប្រាក់ចំនួន ១0000៛ ។ ក្រុមអ្នកលក់ត្រូវត្រួតពិនិត្យអ្វីដែលគេបានលក់ត្រូវស្មើជាមួយលុយដែលគេបានទទួល ។

# ផែបបទទី៦:   ការវិភាគ និង ឆ្លើយតបទៅនឹងកំហុសរបស់សិស្ស

## II. **គោលបំណង** :

- សិក្ខាកាម កំណត់អ្វី ៗ ដែលសិស្សមិនយល់ ដោយវិភាគកំហុសរបស់សិស្ស
- សិក្ខាកាម កែសម្រួលមេរៀនតាមសេចក្តីត្រូវការរបស់សិស្សដោយពឹងផ្អែកលើការវិភាគកំហុសរបស់សិស្សម្នាក់ៗ ។

## III. **រយៈពេល** :

៣ ម៉ោង ។

## IV. **សម្ភារ** :

- ក្រដាសរ៉ាមផ្ទាំងធំ
- ហ្វឺត
- ស្កុត
- ដីហ្សាក្រាមផ្សេង ៗ
- ឯកសារសម្រាប់បែងចែក ។

## V. **លំនាំបង្រៀន** :

### 1. ការអនុវត្តរបស់គ្រូនាពេលបច្ចុប្បន្ននេះ និង ពេលកន្លងមក :

- សូមគិតអំពីវិធីបង្រៀនកន្លងមករបស់គ្រូសម្រាប់ជួយកែលំអសិស្ស ។ មានបង្ហាញគំនិតមួយដូចខាងក្រោម ÷

> ឧទាហរណ៍ : នៅពេលថ្មី ៗ នេះ មិត្តរបស់ខ្ញុំបាននិយាយអំពីបទពិសោធន៍របស់ខ្លួនស្តីពីគ្រូមធ្យមសិក្សា ដែលព្យាយាមជួយគាំទ្រដល់ក្រុមសិស្សស្រី ដែលចូលរួមក្នុងកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ ។ លោកគ្រូបានត្អូញត្អែរថា សិស្សស្រីទាំងនេះពិតជាសិស្សល្ងង់ ពីព្រោះគេមិនអាចយល់ពីអ្វី ៗ ដែលលោកគ្រូបានបង្រៀន ២ ដង រួចមកហើយ ។ លោកគ្រូផ្តល់យោបល់ថា សាលាមធ្យមសិក្សាមិនគួរតែទទួលសិស្សដូចនេះទេ ។

## ករណីសិក្សាសិស្សឈ្មោះ " ភាព "

១. *ព្រឹត្តិការណ៍* : សិស្សឈ្មោះ " ភាព " ដែលរៀននៅថ្នាក់ទី ២ ។ គាត់ជាកុមារដែលមានការសហការយ៉ាងល្អ ។ ស្ថានភាពនៅផ្ទះរបស់គាត់អាចមានឥទ្ធិពលវិជ្ជមានលើការរៀនរបស់គាត់ ។ ប៉ុន្តែ " ភាព " ទទួលពិន្ទុទាបក្នុងការរៀនអំពីប្រមាណវិធីបូកលេខ ។ អ្នកគ្រូបានយល់ថា " ភាព " ជួបការលំបាកនេះជាញឹកញាប់ ដូចនេះអ្នកគ្រូចង់ចំណាយពេលវេលាខ្លះដើម្បីស្វែងយល់អំពីបញ្ហាដែល " ភាព " រៀនខ្សោយផ្នែកគណិតវិទ្យានេះ ។

២. *ការវិភាគជាជំហានទី ១* : ការវិភាគជំហានទី ១ ក្នុបបញ្ហានេះ អ្នកគ្រូបានធ្វើការស្រាវជ្រាវក្នុងឯកសាររបស់គាត់ ឯកសារនេះជាវិញ្ញាសាប្រឡងប្រចាំថ្ងៃដែលសិស្សបានធ្វើក្នុងឆ្នាំសិក្សានេះ ។ អ្នកគ្រូបានមើលឯកសារប្រឡងរបស់ " ភាព " ហើយអ្នកគ្រូបានរៀបចំបញ្ជីលើបញ្ហាដែល " ភាព " បានបូកលេខខុសកន្លងមក :

| | | | | |
|---|---|---|---|---|
| ៨៣ | ៤៣ | ៨ + ១១ = ៩១ | ៣ + ៤៤ = ៧៤ | ២៦ + ៥៣ = ៧៨ |
| - ១៦ | - ៥៥ | ៥ + ១១ = ៦១ | ៤ + ១៥ = ៥៥ | |
| ៩៨ | ៩៧ | ៣ + ៣៥ = ៦៥ | ៦៣ + ៥ = ៦៧ | |

៣. *ការវិភាគជាជំហានទី ២* : អ្នកគ្រូសង្កេតឃើញថា " ភាព " មានបញ្ហា ២ យ៉ាង ។ បញ្ហាទី ១ គឺការបូកលេខ គ្មានចំណេះដឹងមូលដ្ឋាន ( Basic fact ) ( ៣ + ៦ ៣ + ៥ ) និង បញ្ហាទី ២ ការធ្វើប្រមាណវិធីជួរដេក ឧ. ៣៣ + ៤ = ៧៣ " ភាព " ធ្វើខុស ។ ទោះបីជាយ៉ាងណាក៏ដោយ មុននឹងបង្រៀនកែលំអ អ្នកគ្រូបានពិនិត្យឡើងវិញពីការវិភាគរបស់ខ្លួន និង ត្រូវតែវិភាគបន្ថែមទៀត ។ ដូចនេះអ្នកគ្រូបានអានឯកសាររបស់គាត់ម្តងទៀត ដើម្បីពិនិត្យអោយបានឃើញ តើកំហុសរបស់ " ភាព " នេះ ជាកំហុសដែលកើតមានឡើងជាញឹកញាប់ដែរឬទេ ? អ្នកគ្រូសង្កេតឃើញថា ទោះបីជា " ភាព " បានសរសេរ ( ៦ + ៣ = ៨ ) ពីរ លើក " ភាព " បានសរសេរ ៦ + ៣ = ៩ គឺត្រឹមត្រូវបាន ៥ លើក ។ ម្យ៉ាងទៀតទោះបីជា " ភាព " បានសរសេរ ៣ + ៥ = ៧ ពីរ លើក " ភាព " បានសរសេរ ៣ + ៥ = ៨ ត្រឹមត្រូវបាន មួយ លើក ។ ដូចនេះ ការវិភាគលើការយល់ដឹងរបស់ " ភាព " អាចទទួលបាននូវលទ្ធផលយ៉ាងស្មុគស្មាញ ។ " ភាព " មានបញ្ហាដូចខាងក្រោមជាញឹកញាប់ : ៨ + ១១ = ៩៩ ៤ + ១៥ = ៥៥ ៣ + ៤៤ = ៧៤ ប៉ុន្តែ " ភាព " អាចឆ្លើយបាននូវបញ្ហាបានត្រឹមត្រូវជានិច្ច ៥១ + ៧ = ៥៨

២៣ + ២ = ២៥ ៦៣ + ៥ = ៦៧ ( ត្រឹមត្រូវ លើកលែងតែ ការបូកខុសលេខចំណោះដឹងមូលដ្ឋាន ៣ + ៥ = ៧ ) " ភាព " ឆ្លើយបញ្ហាខាងក្រោមនេះត្រឹមត្រូវជានិច្ច : ២០ + ៦ = ២៦ ៥ + ៤០ = ៤៥ ៧ + ១០ = ១៧ ៨ + ២០ = ២៨ ។

៤. ***ការវិភាគជាជំហានទី ៣*** : អ្នកគ្រូបានដាក់បញ្ហាអោយ " ភាព " ធ្វើដូចខាងក្រោម ។ ពេលដែល " ភាព " កំពុងតែធ្វើកិច្ចការនោះ អ្នកគ្រូ ជាអ្នកសង្កេតខាងក្រោយ :

៣០ + ៦ = ៥ + ៧០ = ២៤ + ៥ = ៨ + ១១ =

៥. ***លទ្ធផល*** : " ភាព " ឆ្លើយបញ្ហាទាំងអស់បានត្រឹមត្រូវ លើកលែងតែបញ្ហាចុងក្រោយ ។ ពេល " ភាព " សរសេរចម្លើយខុស ( ៨ + ១១ = ៩១ ) អ្នកគ្រូបានសួរ " ភាព " អោយ " ភាព " ពន្យល់នូវវិធីបូកលេខមកគាត់ ។ ហេតុអ្វីបានជា ៨ + ១១ = ៩១ " ភាព " បានពន្យល់ថា " ខ្ញុំបូក ៨ ហើយនឹង ១ ពីព្រោះវានៅជិតគ្នា ៨ + ១១ = ៩១ " ។

៦. ***ការសន្និដ្ឋាន*** : អ្នកគ្រូយល់ថា " ភាព " ទទួលជោគជ័យ នៅពេលដែលគាត់ដោះស្រាយបញ្ហាដែលទាក់ទងនឹងខ្ទង់ រាយ ឬ ខ្ទង់ ដប់ ។ អ្នកគ្រូគិតឃើញថា " ភាព " ឆ្លើយបញ្ហាដូច ២០ + ៦ និង ៧ + ៤០ បាន

ត្រឹមត្រូវដោយ " ភាព " គិតអំពីខ្ទង់ ដប់ និង ខ្ទង់ រាយ តែប៉ុណ្ណោះ ។ អ្នកគ្រូអាចសន្និដ្ឋានថា " ភាព " ជួបនូវការលំបាកក្នុងវិធីបូកលេខ តាមប្រមាណវិធីជួរដេក ពីព្រោះ " ភាព " ធ្វើតាមប្រព័ន្ធ យកខ្ទង់ រាយ បូកនឹងខ្ទង់ ដប់ ។ ឧ. ៨ + ១១ = ៩១

ក៏ប៉ុន្តែពេលខ្លះ " ភាព " ធ្វើតាមរបៀបខាងលើបានត្រឹមត្រូវ តែទោះជាយ៉ាងណាក៏ដោយ " ភាព " មិនទាន់យល់អំពីវិធាន ឬ ដំណើរការនៃប្រមាណវិធីបូកលេខ ដែលមាន លេខ ពីរ ខ្ទង់ នៅឡើយ ។

៧. ***ដំណោះស្រាយ*** : ..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

# ការបំប៉នសិស្សរៀនយឺត

## 1.Introduction សេចក្តីផ្តើម

ការត្រួតថ្នាក់របស់សិស្សបឋមសិក្សានៅកម្ពុជា គឺជាបញ្ហាចម្បងដែលមាននៅក្នុងប្រពន្ធ័អប់រំកម្ពុជា ជាពិសេសនៅថ្នាក់បឋមសិក្សាកំរិតទាបៗ ( ថ្នាក់ទី ១ ដល់ ថ្នាក់ទី៣) ។ គំរោង វៀជូភ មានសកម្មភាពជាច្រើន ដើម្បីជួយកែលំអគុណភាពអប់រំ និងបង្ករភាពងាយស្រួលចូលសាលារៀនដល់កុមារនៅតំបន់ដាច់ស្រយាល ក្នុងការឆ្លើយតបទៅនឹងគោលដៅអប់រំសម្រាប់ទាំងអស់គ្នារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះមាន កម្មវិធីបំប៉នសិស្សរៀនយឺត សម្រាប់ជួយសិស្សនៅឆមាសទី២នៃឆ្នាំសិក្សា ។

## 2. Objective គោលបំណងនៃកម្មវិធី :

កម្មវិធីនេះមានគោលបំណងរួម ជួយដល់សិស្សដែលរៀនយឺត មានន័យថាសិស្សនោះរៀនខ្សោយ សិស្សពិការ សិស្សកូនអ្នកក្រីក្រ និងសិស្សអសមត្ថភាពក្នុងការសិក្សា អោយរៀនជាប់មធ្យមភាគវិញនៅចុង ឆ្នាំសិក្សា ។

ក្នុងនោះយើងយកចិត្តទុកដាក់ដល់សិស្សដែល ធ្លាក់មធ្យមភាគ ក្នុងឆមាសទីមួយធ្វើយ៉ាង ណាជួយពួកគេរៀនជាប់មធ្យមភាគវិញនៅក្នុងឆមាសទី ២ ។ នៅកម្ពុជាយើងពាក្យដែលថាធ្លាក់ មធ្យមភាគគឺ : សិស្សដែលបានមធ្យមភាគ 4.99 ចុះក្រោម ។

## 3. Target group: ក្រុមគោលដៅ

១.គ្រប់សាលារៀនទាំងអស់នៅក្នុងគោលដៅរបស់កម្មវិធី អេស្កាប់ ដែលមានកំណត់នៅក្នុងផែនការអភិវឌ្ឍកម្រងសាលារៀន ។

២. សិស្សធ្លាក់មធ្យមភាគឆមាសទី១ ពីថ្នាក់ទី ១-៦

## 4. Facilitator អ្នកសម្របសម្រួល

**ដំណាក់កាលទី១:** អ្នកបច្ចេកទេសអេស្កាប់ បណ្តុះបណ្តាលប្រធានក្រុមបច្ចេកទេស ពីថ្នាក់ទី១-៤ ដែលមានរយៈពេល ៣ ថ្ងៃ ។

**ដំណាក់កាលទី២:** ប្រធានក្រុមបច្ចេកទេស បណ្តុះបណ្តាលគ្រូបង្រៀនសិស្សរៀនយឺតដែលបានជ្រើសរើសរួចដោយគណៈកម្មការកម្រង រយៈពេលបណ្តុះបណ្តាល ៣ ថ្ងៃដែរ ។

### 5. Information of implementation ដំណើរការនៃកម្មវិធី :

កម្មវិធីនេះ ចាប់ដំណើរការនៅដើមឆមាសទី ២ ហើយមានរយៈពេល ១៦ សប្តាហ៍ ដោយដកទុកមួយសប្តាហ៍ជាសប្តាហ៍វាយតម្លៃ ។ សិស្សរៀនយឺត គឺជាសិស្សដែលមានបញ្ហាលើការសិក្សា ដូចនេះ យើងត្រូវមានការជ្រើសរើសសិស្សដោយយកចិត្តទុកដាក់បំផុត ( មាននិយាយលំអិតនៅផ្នែកជ្រើសរើសសិស្ស ) ។

ក្នុង1 សប្តាហ៍យើងបង្រៀន 3 ថ្ងៃ និងក្នុងមួយថ្ងៃបង្រៀន 2 ម៉ោង គឺ ម៉ោងភាសាខ្មែរមួយម៉ោង គណិតវិទ្យាមួយម៉ោង ។ ក្នុងមួយម៉ោងគ្រូបង្រៀនទទួលបានថវិកា 2000 រៀល ស្មើ 0.50ដុល្លា សរុបទៅក្នុងមួយសប្តាហ៍គ្រូទទួលថវិកា 12000 រៀលស្មើ 3 ដុល្លារ ។

## ១.ការជ្រើសរើសគ្រូ :

គ្រូដែលត្រូវបានជ្រើសរើសចូលក្នុងកម្មវិធី បំប៉នសិស្សរៀនយឺត គឺជាគ្រូដែលសកម្មក្នុងការងារបង្រៀនសិស្ស ហើយជាគ្រូដែលមានទំនោរលើការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល រឺការបង្រៀនតាមបែបសហការ ។ គ្រូដែលជ្រើសរើសស្ថិតក្នុងចំណោម :

- គ្រូដែលបង្រៀននៅថ្នាក់កុមារមេត្រី
- គ្រូដែលយកចិត្តទុកដាក់បង្រៀនដោយដាក់សិស្សជាក្រុម
- គ្រូដែលមានសម្ភារច្រើនយកមកបង្រៀនសិស្ស
- គ្រូដែលសកម្មក្នុងពេលគោរពម៉ោងបង្រៀនត្រឹមត្រូវតាមការកំណត់របស់ក្រសួង
- គ្រូដែលសកម្មហើយមានជីវភាពយ៉ាប់យឺន
- គ្រូដែលខ្ចីសម្ភារពីបន្ទប់ធនធានច្រើនជាងគេមកបង្រៀនសិស្ស
- គ្រូដែលចេះដឹកនាំសិស្សអោយចេះចូលអាន និងស្រាវជ្រាវក្នុងបណ្ណាល័យ
- គ្រូដែលបង្រៀនសិស្សឡើងថ្នាក់ច្រើនជាងគេ ។

ពេលដែលសំរេចជ្រើសរើសគ្រូ សូមកុំភ្លេចយកឈ្មោះគ្រូទាំងនោះ ទៅប្រជុំពិភាក្សាក្នុងគណៈកម្មការកំរងសាលាដើម្បីសំរេច ជៀសវាងការរើសដោយមិនបានពិភាក្សាក្នុងសមូហភាព នាំអោយមានភាពមិនតំលាភាព ។

## ២.វិធីជ្រើសរើសសិស្ស :

វិធីជ្រើសរើសសិស្ស ត្រូវពិនិត្យមើលក្រោយពីបញ្ចប់ ឆមាសទីមួយ នោះយើងនិងឃើញថា សិស្ស ប៉ុន្មាននាក់ដែលធ្លាក់មធ្យមភាគ ។ ពេលនោះក្រុមបច្ចេកទេសប្រចាំកំរងត្រូវពិភាក្សាជាមួយគណៈកម្មការ កំរង ថាតើយើងត្រូវជួយសិស្សប៉ុន្មានក្រុម ? តាមថវិកាដែលមាន ។ តើគួរជួយក្រុមសិស្សក៏រិតថ្នាក់ណាខ្លះ ? ហើយសំរេចយកសិស្សដែលរៀនខ្សោយបំផុតរឺ ខ្សោយល្មមរឺ ជួយទាំងអស់ ។

ជាទូទៅយើងសូមជូនជាយោបល់ថា ការសំរេចជួយក្រុមក៏រិតថ្នាក់ណាមួយនោះ គួរគណៈកម្មការ កំរងផ្អែកលើ កត្តាភាគរយធ្លាក់មធ្យមភាគខ្ពស់នៅ ក៏រិតថ្នាក់ណាច្រើនជាងគេហើយនៅសាលាណាមានអត្រា ត្រួតថ្នាក់ខ្ពស់ជាងគេ ទើបយើងធ្វើនៅសាលានោះតែម្តង ។ ម្យ៉ាងទៀតកន្លងមកមានកំរងខ្លះ អនុវត្តកម្មវិធី នេះដោយជ្រើសរើសសិស្ស មិនដូចការណែនាំខាងលើនោះទេ។

ចំពោះការជ្រើសរើសសិស្ស មានលក្ខណៈតាមក៏រិតថ្នាក់ដូចតទៅ :

- ថ្នាក់ទី1 ថ្នាក់ទី2 និងថ្នាក់ទី3 :សិស្សមួយក្រុម មានចំនួន 20 នាក់ បើតិចជាងរិតតែប្រសើរ ។
- ថ្នាក់ទី4 ថ្នាក់ទី5 និងថ្នាក់ទី6 :សិស្សមួយក្រុម មានចំនួន 15 នាក់ បើតិចជាងរិតតែប្រសើរ ។
- ក៏ប៉ុន្តែមិនគួរអោយមានសិស្សក្នុងក្រុមតិចជាង 10នាក់នោះទេ ។
- ក្រុមសិស្សគួរជ្រើសរើសសិស្សដែលមានផ្ទះនៅ ជិតៗគ្នា ក្នុងភូមិ ។
- គ្រូគួរចេះនិយាយដោយលើកទឹកចិត្តសិស្ស ដើម្បីអោយពួកគេពេញចិត្តនឹងមករៀនជាក្រុម។

## ៣.វិធីជ្រើសរើសទីកន្លែង :

កន្លែងដែលត្រូវកំនត់រៀន ត្រូវរើសក្រោមផ្ទះប្រជាជន ដែលនៅចំនុចកណ្តាលក្រុមសិស្ស ផ្ទះនោះ ត្រូវមានលក្ខណៈដូចតទៅ :

- ជាកន្លែងដែលមានអនាម័យល្អ និងខ្យល់អាកាសល្អ
- ជាកន្លែងមានពន្លឺគ្រប់គ្រាន់
- ជាកន្លែងដែលមានទីធ្លាធំទូលាយ
- ជាកន្លែងអាចតាំងសម្ភារ និងក្តារខៀនតូចបាន
- ជាកន្លែងដែលអាចក្រាលកន្ទេលបានចំនួន 6 និងសិស្សអង្គុយបានយ៉ាងហោចណាស់ 5 ក្រុម
- ជាកន្លែងដែលមិនមានការរំខានដោយសំឡេង រឺភាពរំខានផ្សេងៗ
- ជាកន្លែងដែលទាក់ទាញសហគមន៏ អាចឃើញ ដឹងលឺ និងចូលរួម ។

ក៏ប៉ុន្តែយើងមិនអនុញ្ញាត អោយរៀបចំក្រុមនៅ កន្លែងក្នុងថ្នាក់រៀន សាលារៀនឡើយ ព្រោះ

វាអាចធ្វើអោយសិស្សមានអារម្មណ៍ខ្មាស់អៀន ភ័យខ្លាច និងសាលារៀនភាគច្រើននៅឆ្ងាយពីផ្ទះរបស់សិស្សផង ។ ហេតុនេះហើយលក្ខណៈល្អនោះ គួរតែរៀបចំកន្លែងរៀននៅក្រោមផ្ទះប្រជាជន ដែលជាការងាយស្រួលអោយសិស្សរៀនយឺតសប្បាយក្នុងការមករៀន មិនខ្លាច ហើយផ្ទះនៅជិតនឹងក្រុម ដែលជាហេតុធ្វើអោយសហគមន៍ចូលរួមដឹងលឺ និងជួយឧបត្ថម្ភគាំទ្រ ។

## ៤.វិធីជួយគ្រូបំប៉នសិស្សរៀនយឺត :

ក្នុងកម្មវិធីនេះ យើងត្រូវជ្រើសរើសក្រុមជួយតាមដាន និងជួយជាជំនួយបច្ចេកទេសបន្ថែមទៀតពីក្រុមបច្ចេកទេសកំរង ក្រុមចំបង ។ ការជួយនេះ ក្នុងមួយសប្តាហ៍ជួយ 2 ដង ដោយពិនិត្យសកម្មភាពបង្រៀនរបស់គ្រូប្រចាំក្រុម និងផ្តល់ពតិមានត្រលប់ ទៅអោយគ្រូប្រចាំក្រុម និងជាអ្នករាយការណ៏មកថ្នាក់លើពេលប្រជុំប្រចាំខែ នីមួយៗ ។ ក្រុមនេះអាចមានសមាសភាព មកពី :

- ក្រុមបច្ចេកទេសប្រចាំកំរង
- ក្រុមចំបង
- គណៈកម្មការកំរង
- តំណាងមន្រ្តីមកពីការិយាល័យអប់រំស្រុក និងមន្រ្តីមកពីអេស្កាប់ ។

## ៥. ការវាយតម្លៃ

មុននឹងចាប់ដំណើរការកម្មវិធីបំប៉នសិស្សរៀនយឺតនេះ កម្រងសាលារៀននីមួយៗត្រូវរៀបចំធ្វើបុរេតេស្ត ជាមុនសិន ដើម្បីស្វែងរកចំនុចខ្សោយនិងចំនុចខ្លាំងរបស់សិស្ស ។ បន្ទាប់មកនៅពាក់កណ្តាលកម្មវិធីបំប៉ន ត្រូវរៀបចំធ្វើតេស្តម្តងទៀត ដើម្បីវាស់ពីការរីកចម្រើនរបស់សិស្ស ។ នៅដំណាក់កាលចុងក្រោយត្រូវរៀបចំធ្វើតេស្តសរុបមួយទៀត ។

វិញ្ញាសារតេស្តនីមួយៗត្រូវរៀបចំដោយគណៈកម្មការបច្ចេកទេសប្រចាំកម្រង ហើយត្រូវរៀបចំកែដោយ ផ្លាស់ប្តូរគ្នា ។

ការរៀបចំដំណើរការបំប៉ននេះ ត្រូវមានការចូលរួមសហការគ្នារវាង ការិយាល័យអប់រំស្រុក ប្រធាន កម្រងសមាជិកក្រុមចម្បង នាយកសាលានីមួយៗក្នុងកម្រង និងគ្រូបង្រៀនបំប៉នផ្ទាល់ ។

ចំពោះការចាត់ចែងថវិកា ត្រូវពិនិត្យទៅតាមថវិកាដែលបានកំណត់ក្នុងផែនការអភិវឌ្ឍកម្រងសាលា ។

ឈឈឈ☺ចចច